ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

# ផែនការយុទ្ធសាស្ត្រ
# អភិវឌ្ឍន៍
# ២០២២-២០២៦

# មាតិកា


**អារម្ភកថា** ........ ១

**សេចក្តីសង្ខេប** ........ ៣

**ផ្នែកទី១ សេចក្តីផ្តើម** ........ ៥

១.១. ក្របខណ្ឌច្បាប់ ........ ៥

១.២. រចនាសម្ព័ន្ធស្ថាប័ន ........ ៥

១.៣. ទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធខាងក្រៅ ........ ៦

**ផ្នែកទី២ លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជំណាក់កាលទី៣ (ឆ្នាំ២០១៧ ដល់ឆ្នាំ២០២១)** ........ ៧

២.១. លទ្ធផលសម្រេចបាន ........ ៧

២.២. កត្តាជោគជ័យ និងបញ្ហាប្រឈមនៃការអនុវត្តផែនការយុទ្ធសាស្ត្រ ........ ៩

**ផ្នែកទី៣ ក្របខណ្ឌរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជំណាក់កាលទី៤ (ឆ្នាំ២០២២-ឆ្នាំ២០២៦)** ........ ១០

**ផ្នែកទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជំណាក់កាលទី៤ (ឆ្នាំ២០២២ -ឆ្នាំ២០២៦)** ........ ១៣

៤.១. ចក្ខុវិស័យ ........ ១៣

៤.២. បេសកកម្ម ........ ១៣

៤.៣. តម្លៃស្នូល ........ ១៣

៤.៤. គោលបំណង ........ ១៥

៤.៥. គោលដៅយុទ្ធសាស្ត្រ ........ ១៨

៤.៦. ផែនការសកម្មភាព ........ ២២

**ផ្នែកទី៥ ការគ្រប់គ្រង និង ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ** ........ ៣៥

៥.១. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ........ ៣៥

៥.២. របាយការណ៍វឌ្ឍនភាពរបស់នាយកដ្ឋាន ........ ៣៧

៥.៣. របាយការណ៍លទ្ធផលប្រចាំឆ្នាំ ........ ៣៨

**ឧបសម្ព័ន្ធទី១៖ ទម្រង់គំរូនៃផែនការសកម្មភាពប្រចាំឆ្នាំ** ........ ៣៩

**ឧបសម្ព័ន្ធទី២៖ គម្រោងថវិកា (ឆ្នាំ២០២២-ឆ្នាំ២០២៦)** ........ ៤០

# អារម្ភកថា

អាជ្ញាធរសវនកម្មជាតិ គឺជាស្ថាប័នសវនកម្មកំពូលនៃព្រះរាជាណាចក្រកម្ពុជាដែលបំពេញមុខងារជាសវនកម្មផ្ទៃក្រៅចំពោះរាជរដ្ឋាភិបាល និងបានចាប់ផ្តើមដំណើរការចាប់តាំងពីឆ្នាំ ២០០១ មកក្នុងស្មារតីនៃចក្ខុវិស័យ *"ជួយរាជរដ្ឋាភិបាលគ្រប់គ្រងធនធានសាធារណៈ ប្រកបដោយភាពស័ក្តិសិទ្ធិ និងជួយលើកការទទួលខុសត្រូវផ្នែកសាធារណៈ តាមរយៈការធ្វើសវនកម្មប្រកបដោយគុណភាព ទាន់ពេលវេលា និងជឿទុកចិត្ត"*។

អាជ្ញាធរសវនកម្មជាតិបំពេញការងារសវនកម្មផ្ទៃក្រៅប្រកបដោយគុណភាព និងវិជ្ជាជីវៈ ដែលជាយន្តការដ៏ស័ក្តិសិទ្ធិក្នុងការចង្អុលបង្ហាញនូវភាពខ្វះចន្លោះ និងការផ្តល់អនុសាសន៍កែលម្អ។ កិច្ចការនេះសម្រេចបានតាមរយៈការអភិវឌ្ឍជាបន្តបន្ទាប់ទាំងលើសមត្ថភាពវិជ្ជាជីវៈសវនកម្ម និងលើការអភិវឌ្ឍស្ថាប័ន។ ក្នុងន័យនេះ អាជ្ញាធរសវនកម្មជាតិបានរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់រយៈពេលប្រាំឆ្នាំម្តង ចាប់តាំងពីឆ្នាំ២០០៧មក។ គិតត្រឹមឆ្នាំ២០២១ ផែនការយុទ្ធសាស្ត្រនេះត្រូវបានសម្រេចអនុវត្តបានបីដំណាក់កាលរួចមកហើយ និងបានសម្រេចលទ្ធផលគួរជាទីមោទនៈ។ ជាក់ស្តែង តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាក់កាលទី៣ ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ អាជ្ញាធរសវនកម្មជាតិ សម្រេចបាននូវលទ្ធផលសំខាន់ៗគួរឱ្យកត់សម្គាល់ ដូចជា ការបន្តកសាង និងពង្រឹងសមត្ថភាពវិជ្ជាជីវៈរបស់សវនករលើជំនាញសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ សវនកម្មលើកិច្ចប្រតិបត្តិការ និងសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ, ការបន្តលើកកម្ពស់គុណភាពការងារសវនកម្មឱ្យស្របតាមស្តង់ដារសវនកម្ម, ការពង្រឹងការគ្រប់គ្រងធនធានមនុស្ស, ការបង្កើនការយល់ដឹងអំពីភារកិច្ច និងតួនាទីសវនកម្មផ្ទៃក្រៅ ដើម្បីធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការពីអង្គភាពរងសវនកម្ម និងស្ថាប័នពាក់ព័ន្ធ, ការអភិវឌ្ឍជាជំហានៗនូវប្រព័ន្ធព័ត៌មានវិទ្យាគាំទ្រដល់ការងារសវនកម្ម, និងការបន្តចូលរួមក្នុងតំបន់ និងអន្តរជាតិ ដើម្បីផ្លាស់ប្តូរ និងចែករំលែកចំណេះដឹង និងជំនាញវិជ្ជាជីវៈ។ ការសម្រេចបាននូវសមិទ្ធផលទាំងអស់នេះបានជួយលើកកម្ពស់ការចូលរួមចំណែករបស់អាជ្ញាធរសវនកម្មជាតិកាន់តែប្រសើរឡើងក្នុងការលើកស្ទួយអភិបាលកិច្ចល្អ និងការបង្កើនប្រសិទ្ធភាពការងារនៃវិស័យសាធារណៈ ក៏ដូចជាការរួមចំណែកដល់ការសម្រេចបានដោយជោគជ័យនូវការអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយ និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល តាមរយៈការធ្វើរបាយការណ៍សវនកម្មប្រកបដោយគុណភាព ទាន់ពេលវេលា និងជឿទុកចិត្តជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល។

ទោះបីជាយ៉ាងនេះក៏ដោយ អាជ្ញាធរសវនកម្មជាតិក៏នៅបន្តកំណត់អាទិភាពខ្ពស់លើការងារលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈ និងការអភិវឌ្ឍស្ថាប័ន ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ស្ថាប័ន និងការវិវត្តលឿនរហ័សទាំងក្នុងប្រទេស និងជាអន្តរជាតិ ដូចជា ការកើនឡើងនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់ការផ្តល់សេវាសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការ

ប្តេជ្ញាចិត្តអនុវត្តគោលដៅប្រកបដោយចីរភាពជាដើម។ ក្នុងន័យនេះ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាក់កាលទី៤ សម្រាប់ឆ្នាំ២០២២ ដល់ឆ្នាំ២០២៦** ត្រូវបានរៀបចំឡើងក្នុងគោលដៅនាំមកនូវការផ្លាស់ប្តូរសំខាន់ៗក្នុងកិច្ចប្រតិបត្តិការ តាមរយៈការដាក់ចេញនូវគោលបំណង និងគោលដៅយុទ្ធសាស្ត្រ សម្រាប់តម្រង់ទិសការអនុវត្តសកម្មភាពអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈសវនកម្ម និងជំនាញពាក់ព័ន្ធ ក៏ដូចជាការអភិវឌ្ឍ និងការពង្រឹងសេវាគាំទ្រចាំបាច់នានា ដែលជួយលើកកម្ពស់ការងារសវនកម្មឱ្យកាន់តែមានគុណភាព ទាន់ពេលវេលា និងជឿទុកចិត្ត។

ភាពជោគជ័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍នេះ តម្រូវឱ្យមានការចូលរួម និងការសហការពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋសភា ព្រឹទ្ធសភា និងជាពិសេសរាជរដ្ឋាភិបាល ដែលតែងតែជួយគាំទ្រយ៉ាងពេញទំហឹង និងសូមអរគុណផងដែរចំពោះកិច្ចសហការជិតស្និទ្ធពីអង្គភាពរងសវនកម្ម និងសាធារណជន។ ព្រមជាមួយនេះ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះគ្រប់ភាគីពាក់ព័ន្ធខាងក្រៅព្រមទាំងស្ថាប័នសវនកម្មកំពូលនានាទាំងក្នុងតំបន់ និងអន្តរជាតិ ដែលបានគាំទ្រទាំងផ្នែកបច្ចេកទេស និងសម្ភារ ក្នុងដំណើរការអភិវឌ្ឍរបស់អាជ្ញាធរសវនកម្មជាតិនាពេលកន្លងមក និងបច្ចុប្បន្ន ក៏ដូចជាទៅអនាគត។

ជាមួយគ្នានេះ ខ្ញុំសូមសំដែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនៃអាជ្ញាធរសវនកម្មជាតិទាំងអស់ ដែលបានចូលរួមចំណែករៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាក់កាលទី៤ (ឆ្នាំ២០២២ - ២០២៦) នេះឱ្យបានសម្រេចជាស្ថាពរ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំចំពោះការខិតខំយកចិត្តទុកដាក់បន្តទៀត និងការបន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះឱ្យបានជោគជ័យ ប្រកបដោយការទទួលខុសត្រូវខ្ពស់ សម្រាប់ជាឧត្តមប្រយោជន៍ដល់ការគ្រប់គ្រងធនធានសាធារណៈ និងគណនេយ្យភាពសាធារណៈ ក៏ដូចជាដល់ប្រជាជនកម្ពុជាទាំងមូល។

ថ្ងៃពុធ ៩រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២

**អគ្គសវនករ**

**សោម គឹមសួគ៌**

# សេចក្តីសង្ខេប

អាជ្ញាធរសវនកម្មជាតិត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អាជ្ញាធរសវនកម្មជាតិ គឺជាស្ថាប័នសវនកម្មកំពូលមានភាពឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចអនុវត្តមុខងារសវនកម្មផ្ទៃក្រៅចំពោះរាជរដ្ឋាភិបាល។

ឆ្នាំ២០២១ ជាឆ្នាំចុងក្រោយនៃការអនុវត្តផែនការយុទ្ធសាស្ត្រការអភិវឌ្ឍន៍ ដំណាក់កាលទី៣ របស់អាជ្ញាធរសវនកម្មជាតិដែលបានចាប់ផ្តើមនៅក្នុងឆ្នាំ២០១៧។ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជំណាក់ទី៣ កន្លងមកមានសកម្មភាពជាច្រើនដែលបានដាក់ចេញត្រូវបានអនុវត្ត និងទទួលលទ្ធផលគួរជាទីមោទនៈ។ សកម្មភាពចម្បងៗដែលបានអនុវត្តគឺដើម្បីរួមចំណែកលើកស្ទួយអភិបាលកិច្ចល្អ និងការប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទោះជាយ៉ាងនេះក្តី ក្នុងរយៈពេល៥ឆ្នាំ នៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ កន្លងមកអាជ្ញាធរសវនកម្មជាតិបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចជា កង្វះខាតហិរញ្ញវត្ថុ ធនធានមនុស្សនៅមានកម្រិត និងការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ជាដើម។

អាជ្ញាធរសវនកម្មជាតិនៅតែយកចិត្តទុកដាក់ជាអតិបរិមាលើការងារបន្តអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈ និងការអភិវឌ្ឍស្ថាប័ន ដើម្បីលើកកម្ពស់គុណភាពនៃការងារសវនកម្ម និងជំរុញការអនុវត្តអនុសាសន៍សវនកម្ម។ នៅក្នុងបរិការណ៍នេះ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដំណាក់កាលទី៤** របស់អាជ្ញាធរសវនកម្មជាតិ សម្រាប់អនុវត្តចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៦ ត្រូវបានរៀបចំ ដោយមាន ៥ផ្នែក៖ ផ្នែកទី១: សេចក្តីផ្តើម ផ្នែកទី២: លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាក់កាលទី៣ ផ្នែកទី៣: ក្របខណ្ឌរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាក់កាលទី៤ ផ្នែកទី៤: ចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល គោលបំណង គោលដៅ យុទ្ធសាស្ត្រ និងផែនការសកម្មភាពចម្បងៗសម្រាប់រយៈពេល ៥ឆ្នាំ របស់អាជ្ញាធរសវនកម្មជាតិ និងផ្នែកទី៥: ការគ្រប់គ្រង ការត្រួតពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តសកម្មភាពនានានៃផែនការយុទ្ធសាស្ត្រនេះ។

# ក្របខណ្ឌយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ សម្រាប់ឆ្នាំ ២០២២ ដល់ឆ្នាំ ២០២៦

**ចក្ខុវិស័យ**

«ជួយរាជរដ្ឋាភិបាលគ្រប់គ្រងធនធានសាធារណៈប្រកបដោយភាពស័ក្តិសិទ្ធិ និងជួយលើការទទួលខុសត្រូវផ្នែកសាធារណៈ តាមរយៈការធ្វើសវនកម្មប្រកបដោយគុណភាព ទាន់ពេលវេលា និងជឿទុកចិត្ត»

**បេសកកម្ម**

«អាជ្ញាធរសវនកម្មជាតិអនុវត្តមុខងារសវនកម្មផ្ទៃក្រៅចំពោះរាជរដ្ឋាភិបាលប្រកបដោយឯករាជ្យភាព និងសមត្ថភាពវិជ្ជាជីវៈខ្ពស់ ដើម្បីសម្រេចបាននូវលទ្ធផលសវនកម្មប្រកបដោយគុណភាព ទាន់ពេលវេលា និងជឿទុកចិត្ត»

**តម្លៃស្នូល**

**«ឯករាជ្យភាព សុចរិតភាព សមត្ថភាពវិជ្ជាជីវៈ តម្លាភាព និងការទទួលខុសត្រូវ»**

**គោលបំណង**

- កសាង និងពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងគុណភាពសវនកម្ម ដើម្បីរួមចំណែកកាន់តែប្រសើរក្នុងការលើកកម្ពស់អភិបាលកិច្ចល្អក្នុងវិស័យសាធារណៈ
- លើកកម្ពស់ការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស ដើម្បីផ្តល់សេវាគាំទ្រកាន់តែប្រសើរដល់ការងារសវនកម្ម
- ពង្រឹងទំនាក់ទំនងរវាងសវនកម្មផ្ទៃក្រៅ និងផ្ទៃក្នុង ព្រមទាំងភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិ ដើម្បីបង្កើនស័ក្តិសិទ្ធិភាពនៃលទ្ធផលសវនកម្ម

➢ គោលដៅយុទ្ធសាស្ត្រ
➢ ផែនការសកម្មភាព ៥ឆ្នាំ
➢ ផែនការសកម្មភាពប្រចាំឆ្នាំ

# ផ្នែកទី១
# សេចក្ដីផ្ដើម

## ១.១. ក្របខណ្ឌច្បាប់

អាជ្ញាធរសវនកម្មជាតិ មានអក្សរកាត់ជាភាសាខ្មែរ "អ.ស.ជ" ជាស្ថាប័នសវនកម្មកំពូលមានភាពឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ មានភារកិច្ចអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល និងត្រូវបានបង្កើតឡើងដោយច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អាជ្ញាធរសវនកម្មជាតិមានថវិកាដោយឡែករបស់ខ្លួនផ្ដល់ដោយថវិកាជាតិ។ ការគ្រប់គ្រងចំណូល និងចំណាយនៃអាជ្ញាធរសវនកម្មជាតិស្ថិតនៅក្រោមច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ។

ច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាបានផ្ដល់ឱ្យអាជ្ញាធរសវនកម្មជាតិនូវសិទ្ធិអំណាចក្នុងការអនុវត្តសវនកម្ម ដែលមានវិសាលភាពពេញលេញលើផ្នែកសាធារណៈ ដូចជាសវនកម្មលើកិច្ចបញ្ជីកាគណនេយ្យ គណនី ប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្ដាក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ជារួម អាជ្ញាធរសវនកម្មជាតិអនុវត្តនូវសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ សវនកម្មលើកិច្ចប្រតិបត្តិការ និងសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ហើយធ្វើរបាយការណ៍សវនកម្មជូនរដ្ឋសភា ព្រឹទ្ធសភា និងចម្លងជូនទៅរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធដើម្បីបានជ្រាប ក្នុងគោលដៅជំរុញឱ្យមានការកែលម្អប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងទាំងឡាយ ចំណុចខ្វះខាត ឬភាពមិនប្រក្រតីនៅក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន។ របាយការណ៍ដែលធ្វើដោយអគ្គសវនករត្រូវបានចាត់ទុកជាឯកសារសាធារណៈ។

## ១.២. រចនាសម្ព័ន្ធស្ថាប័ន

អាជ្ញាធរសវនកម្មជាតិដឹកនាំដោយអគ្គសវនករមួយរូប និងមានអគ្គសវនកររងពីររូប មានអគ្គលេខាធិការដ្ឋាន ព្រមទាំងនាយកដ្ឋានចំនួនប្រាំមួយ។ អគ្គសវនករមានតួនាទីជាអ្នកដឹកនាំអាជ្ញាធរសវនកម្មជាតិទទួលខុសត្រូវលើការអនុវត្តគោលនយោបាយ គោលដៅ និងគោលបំណងរបស់អាជ្ញាធរសវនកម្មជាតិ ព្រមទាំងមានសិទ្ធិធ្វើសកម្មភាពលើរាល់កិច្ចការទាំងអស់ដែលមានចែងក្នុងច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ អគ្គសវនករជាអ្នកតែងតាំង ផ្លាស់ប្ដូរ ធ្វើកម្មវិបាក និងកំណត់បៀវត្ស អត្ថប្រយោជន៍ ប្រាក់កម្រៃ ប្រាក់រង្វាន់ ដល់មន្ត្រីរាជការ និងបុគ្គលិករបស់អាជ្ញាធរសវនកម្មជាតិ។

ការគ្រប់គ្រងមន្ត្រីនៃអាជ្ញាធរសវនកម្មជាតិផ្អែកលើលក្ខន្តិកៈដោយឡែកស្ដីពីក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ ដែលត្រូវបានដាក់ឱ្យអនុវត្តដោយព្រះរាជក្រឹត្យលេខនស/រកត/០៨០៩/៨៣៩ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ និងសៀវភៅណែនាំស្ដីពីការគ្រប់គ្រងធនធានមនុស្ស។ ទន្ទឹមនឹងនេះ មន្ត្រីនៃអាជ្ញាធរសវនកម្មជាតិត្រូវគោរពតាមក្រមសីលធម៌ បទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរសវនកម្មជាតិ និងលិខិតបទដ្ឋានគតិយុត្តនានា។

ការគ្រប់គ្រងធនធានមនុស្សរបស់អាជ្ញាធរសវនកម្មជាតិ គឺជាចក្ខុវិស័យចម្បងមួយ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ហើយក៏ជាយុទ្ធសាស្រ្តដើម្បីពង្រឹង និងកសាងសមត្ថភាពស្ថាប័នក្នុងការបំពេញការងារសវនកម្មប្រកបដោយវិជ្ជាជីវៈ គុណភាព និងប្រសិទ្ធភាព។ អាជ្ញាធរសវនកម្មជាតិបាន និងកំពុងខិតខំប្រឹងប្រែងពង្រឹងសមត្ថភាពមន្ត្រីតាមរយៈការបណ្តុះបណ្តាលជំនាញសវនកម្មជាជំហានៗទាំងក្នុង និងក្រៅប្រទេស ដើម្បីឱ្យស្របតាមស្តង់ដារសវនកម្មអន្តរជាតិ និងការវិវត្តរបស់វិស័យសវនកម្មសាធារណៈ ព្រមទាំងសមស្របតាមស្ថានភាពជាក់ស្តែងរបស់ប្រទេសកម្ពុជា។

ទោះបីជាមានការបណ្តុះបណ្តាលទាំងក្នុង និងខាងក្រៅប្រទេសយ៉ាងណាក៏ដោយ តម្រូវការបន្តពង្រឹងសមត្ថភាពសវនករនៅតែចាំបាច់ ដើម្បីសម្របទៅតាមការវិវត្តរបស់សង្គម និងការរីកចម្រើននៃបច្ចេកវិទ្យា។

## ១.៣. ទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធខាងក្រៅ

ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធខាងក្រៅ គឺជាសមាសធាតុយ៉ាងសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវកិច្ចដំណើរការ និងគុណភាពការងាររបស់អាជ្ញាធរសវនកម្មជាតិ។ កិច្ចសហការដ៏ល្អប្រពៃពីក្រសួង ស្ថាប័នសាធារណៈ និងអង្គភាពរងសវនកម្មដទៃទៀត និងការយកចិត្តទុកដាក់អនុវត្តអនុសាសន៍សវនកម្ម គឺជាភាពចាំបាច់សម្រាប់ធានាភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពការងារសវនកម្ម។ ទន្ទឹមគ្នានេះ ការគាំទ្រពីសំណាក់រដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលក្នុងការជំរុញឱ្យអង្គភាពរងសវនកម្មចាត់វិធានការកែលម្អតាមអនុសាសន៍សវនកម្ម គឺជាការរួមចំណែកយ៉ាងខ្លាំងក្នុងការលើកកម្ពស់ការគ្រប់គ្រងធនធានសាធារណៈប្រកបដោយគណនេយ្យភាព តម្លាភាព និងអភិបាលកិច្ចល្អ។

អាជ្ញាធរសវនកម្មជាតិបានចូលជាសមាជិករបស់អង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល (International Organization for Supreme Audit Institutions – INTOSAI) នាឆ្នាំ២០០៣, អង្គការអាស៊ីនៃស្ថាប័នសវនកម្មកំពូល (Asian Organization for Supreme Audit Institutions – ASOSAI) នាឆ្នាំ២០០៤ និងស្ថាប័នសវនកម្មកំពូលអាស៊ាន (ASEAN Supreme Audit Institution – ASEANSAI) នាឆ្នាំ២០១១។

អាជ្ញាធរសវនកម្មជាតិបានធ្វើជាប្រធាន ASEANSAI ដែលមានអាណត្តិ ២ឆ្នាំ ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧។ តាមរយៈកិច្ចការទាំងនេះ អាជ្ញាធរសវនកម្មជាតិមានឱកាសទទួលបាននូវបទពិសោធន៍ និងឧត្តមានុវត្តន៍ពីបណ្តាស្ថាប័នសវនកម្មកំពូលនានាក្នុងតំបន់ និងអន្តរជាតិ។

# ផ្នែកទី ២
# លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដំណាក់កាលទី៣ ( ឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ )

## ២.១. លទ្ធផលសម្រេចបាន

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដំណាក់កាលទី៣ ( ឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ) របស់អាជ្ញាធរសវនកម្មជាតិ (អ.ស.ជ) ត្រូវបានអនុម័តដាក់ឱ្យអនុវត្តនៅក្នុងខែឧសភា ឆ្នាំ២០១៧។ ផែនការនេះបានដាក់ចេញនូវគោលបំណងចំនួន ៥ និងគោលដៅយុទ្ធសាស្ត្រចំនួន ១៧ ដោយគោលដៅយុទ្ធសាស្ត្រនីមួយៗបានកំណត់នូវសកម្មភាពចម្បងៗ ដែលសរុបមានចំនួន ៦៣ សកម្មភាព ដែលមានគោលបំណងបន្តលើកកម្ពស់សមត្ថភាពស្ថាប័ន និងវិជ្ជាជីវៈសវនកម្ម ដើម្បីរួមចំណែកលើកស្ទួយអភិបាលកិច្ចល្អ និងការប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាពខ្ពស់។

គិតត្រឹមខែធ្នូ ឆ្នាំ២០២១ ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម៖

➢ **គោលបំណងទី១៖ កសាង និងពង្រឹងសមត្ថភាពវិជ្ជាជីវៈ ព្រមទាំងគុណភាពសវនកម្ម**

គោលបំណងនេះ ត្រូវបានកំណត់ដើម្បីគាំទ្រដល់ការងារអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ សវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ និងសវនកម្មលើកិច្ចប្រតិបត្តិការ។ ទន្ទឹមនឹងនេះ គោលបំណងនេះក៏ផ្តោតការយកចិត្តទុកដាក់លើការងារត្រួតពិនិត្យគុណភាពសវនកម្ម ការធានាគុណភាពសវនកម្ម ការតាមដានអនុសាសន៍សវនកម្ម និងការទុកដាក់ឯកសារសវនកម្ម។ ដើម្បីសម្រេចបាននូវគោលបំណងដែលបានដាក់ចេញ អ.ស.ជ បានកំណត់នូវគោលដៅយុទ្ធសាស្ត្រចំនួន ៦ និងសកម្មភាពចម្បងៗចំនួន ៣១។ ជាលទ្ធផល អ.ស.ជ សម្រេចអនុវត្តបានពេញលេញលើសកម្មភាពចំនួន ១៧ និងមានសកម្មភាពចំនួន ៩ កំពុងបន្តអនុវត្ត ដូចជាការងាររៀបចំកម្មវិធីនិងឯកសារបណ្តុះបណ្តាល ការបណ្តុះបណ្តាលជំនាញសវនកម្ម ការបំពាក់បំប៉នជំនាញបន្ថែមសម្រាប់គ្រូបង្គោល ការរៀបចំនិងដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំសវនកម្ម ការអនុវត្តនូវនីតិវិធីត្រួតពិនិត្យគុណភាពសវនកម្មក្នុងកម្រិតនាយកដ្ឋាន និងការអនុវត្តការងារសវនកម្មស្របតាមគោលការណ៍ណែនាំសវនកម្ម។ ដោយឡែក សកម្មភាពចំនួន ៥ ផ្សេងទៀត មានវឌ្ឍនភាពតិចតួចដែលចាំបាច់ត្រូវបន្តអនុវត្ត និងលើកទៅអនុវត្តសម្រាប់ផែនការយុទ្ធសាស្ត្របន្ទាប់រួមមាន៖ ការត្រួតពិនិត្យគុណភាព និងការធានាគុណភាពសវនកម្ម និងគោលការណ៍ណែនាំស្តីពីការតាមដានការអនុវត្តអនុសាសន៍សវនកម្ម។

## ➢ គោលបំណងទី២៖ ពង្រឹងការគ្រប់គ្រងធនធានមនុស្ស

គោលបំណងនេះផ្តោតលើការពង្រឹងសេវាគាំទ្រដល់ការងារសវនកម្មដែលជាភារកិច្ចស្នូល របស់ អ.ស.ជ។ គោលដៅយុទ្ធសាស្ត្រចំនួន ៣ និងសកម្មភាពចម្បងៗចំនួន១២ ត្រូវបានកំណត់ ដើម្បីពង្រឹងការអនុវត្តសៀវភៅណែនាំស្តីពីការគ្រប់គ្រងធនធានមនុស្ស ការបង្កើនគុណភាពបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការបណ្តុះបណ្តាល។ ជាលទ្ធផល មានសកម្មភាពចម្បងៗចំនួន ៨ បានសម្រេចរួចហើយ។ សកម្មភាពសេសសល់ផ្សេងទៀតសម្រេចដោយផ្នែក និងមានវឌ្ឍនភាពយឺត រួមមានការតម្លើងប្រព័ន្ធរក្សាទុក និងគ្រប់គ្រងទិន្នន័យ និងការវាយតម្លៃមន្ត្រី។

## ➢ គោលបំណងទី៣៖ លើកកម្ពស់ការយល់ដឹងរបស់សាធារណជនលើមុខងារសវនកម្មផ្ទៃក្រៅ និងការទំនាក់ទំនងខាងក្រៅជាមួយភាគីពាក់ព័ន្ធ

អ.ស.ជ បានដាក់ចេញនូវគោលបំណងនេះដើម្បីបង្កើនភាពទាន់ពេលវេលា ប្រសិទ្ធភាព និងគុណភាពនៃការងារសវនកម្ម តាមរយៈការបញ្ជ្រាបការយល់ដឹងកាន់តែស៊ីជម្រៅអំពីភារកិច្ច និងតួនាទីសវនកម្មផ្ទៃក្រៅជូនដល់អង្គភាពរងសវនកម្ម និងភាគីពាក់ព័ន្ធខាងក្រៅផ្សេងទៀត។ ការទំនាក់ទំនងយ៉ាងទៀងទាត់ជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងភាគីពាក់ព័ន្ធខាងក្រៅក៏ត្រូវបានកំណត់ជាយុទ្ធសាស្ត្រនៅក្នុងគោលបំណងនេះផងដែរ។ ជារួម គោលបំណងទី៣នេះបានដាក់ចេញគោលដៅយុទ្ធសាស្ត្រចំនួន ៤ និងសកម្មភាពចម្បងៗចំនួន ១១។ ជាលទ្ធផល អ.ស.ជ សម្រេចអនុវត្តបានសកម្មភាពចម្បងៗចំនួន ១០ ដូចជាការងាររៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដារសវនកម្មសាធារណៈជូនក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្នែកឯកជនពាក់ព័ន្ធ, ការដាក់ចេញនូវគោលនយោបាយទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ, និងការបំពេញតួនាទីជាប្រធាន ASEANSAI ដែលមានភាពសកម្ម និងមានវិជ្ជាជីវៈ។ សកម្មភាពចំនួន ១ កំពុងបន្តអនុវត្តលើការពិនិត្យតាមដានកិច្ចទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ។

## ➢ គោលបំណងទី៤៖ អភិវឌ្ឍ និងថែទាំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការងាររដ្ឋបាល និងការងារសវនកម្ម

គោលបំណងនេះបានកំណត់នូវគោលដៅយុទ្ធសាស្ត្រចំនួន ៣ និងសកម្មភាពចម្បងៗចំនួន ៧ ដើម្បីប្រើប្រាស់នូវទំនើបកម្មនៃប្រព័ន្ធព័ត៌មានវិទ្យាគាំទ្រដល់ការងាររដ្ឋបាល និងការងារសវនកម្ម ដូចជាប្រព័ន្ធអ៊ីនត្រាណែត គេហទំព័រ ប្រព័ន្ធគ្រប់គ្រងបុគ្គលិក ប្រព័ន្ធគ្រប់គ្រងការតាមដានអនុសាសន៍សវនកម្ម ប្រព័ន្ធ FMIS សម្រាប់ការងារហិរញ្ញវត្ថុរបស់អ.ស.ជ ព្រមទាំងការស្តារ និងថែទាំគ្រឿងបរិក្ខារព័ត៌មានវិទ្យា និងដំណោះស្រាយ។ ជាលទ្ធផល មានសកម្មភាពចម្បងៗចំនួន ៣ បានសម្រេចរួចហើយ សកម្មភាពចំនួន ១ កំពុងបន្តអនុវត្ត និងសកម្មភាពចំនួន ៣ មានវឌ្ឍនភាពតិចតួច រួមមាន៖ (១) ការតម្លើងប្រព័ន្ធអ៊ីនត្រាណេត ដើម្បីសម្រួលដល់ការងារទំនាក់ទំនងផ្ទៃក្នុង និងការគ្រប់គ្រងគេហទំព័រ (២) ការតម្លើងប្រព័ន្ធគ្រប់គ្រងបុគ្គលិក និង (៣) ការតម្លើងប្រព័ន្ធគ្រប់គ្រងការតាមដានអនុសាសន៍សវនកម្ម។

➢ **គោលបំណងទី៥ ៖ រួមចំណែក និងចូលរួមសិក្សាអំពីវិជ្ជាជីវៈសវនកម្មក្នុងបរិបទអន្តរជាតិ**

គោលបំណងនេះត្រូវបានកំណត់ដើម្បីជានាបាននូវការផ្ដល់ឱកាសដល់មន្ត្រី អ.ស.ជ ក្នុងការចូលរួមក្នុងព្រឹត្តិការណ៍នានានៅក្នុងឆាកអន្តរជាតិដែលរៀបចំដោយស្ថាប័នវិជ្ជាជីវៈ អង្គការអន្តរជាតិផ្សេងៗ និងការចែករំលែកនូវបទពិសោធន៍ និងចំណេះដឹងដល់មន្ត្រី អ.ស.ជ ផ្សេងទៀត។ ដើម្បីសម្រេចបាននូវគោលបំណងនេះ អ.ស.ជ បានដាក់ចេញ និងបានអនុវត្តដោយពេញលេញនូវគោលដៅយុទ្ធសាស្ត្រចំនួន ១ និងសកម្មភាពចម្បងៗចំនួន ២។

ជារួម ក្រោមការដឹកនាំ លើកទឹកចិត្ត សម្របសម្រួល និងការគាំទ្រពីថ្នាក់ដឹកនាំ រួមជាមួយនឹងការខិតខំប្រឹងប្រែង ព្រមទាំងការយកចិត្តទុកដាក់អនុវត្តរបស់បណ្ដានាយកដ្ឋាន និងក្រុមការងារពាក់ព័ន្ធ និងទោះបីជាមានបញ្ហាប្រឈមរាំងស្ទះដល់ការអនុវត្តមួយចំនួនក៏ដោយ អ.ស.ជ នៅតែបានអនុវត្តនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ សម្រាប់ឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ដោយទទួលបាននូវលទ្ធផលច្រើនគួរជាទីមោទនៈ។

## ២.២. កត្តាជោគជ័យ និងបញ្ហាប្រឈមនៃការអនុវត្តផែនការយុទ្ធសាស្ត្រ

ក្នុងការអនុវត្តនូវផែនការសកម្មភាពដែលគាំទ្រដល់ការសម្រេចបាននូវគោលបំណង និងគោលដៅយុទ្ធសាស្ត្រដែលបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កន្លងមក អ.ស.ជ សម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់។ ទោះបីជាយ៉ាងនេះក៏ដោយ បញ្ហាប្រឈមក៏កើតមានឡើងផងដែរ ដែលបានបង្អាក់ដំណើរដល់សកម្មភាពមួយចំនួន។ ជាការសន្និដ្ឋានចេញពីបទពិសោធន៍នៃការអនុវត្តផែនការយុទ្ធសាស្ត្រកន្លងមក យើងសង្កេតឃើញថា មានកត្តាមួយចំនួន និងអាចមានលើសពីនេះទៀត ដែលជួយទ្រទ្រង់ដល់ភាពជោគជ័យ និងរាំងស្ទះដល់ដំណើរការអនុវត្តផែនការសកម្មភាព។

- ***<u>កត្តាជោគជ័យ</u>***

១. ការផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទៅនឹងការគ្រោងថវិកាប្រចាំឆ្នាំ និងផែនការសកម្មភាពនៃការអនុវត្តកម្មវិធីកែទម្រង់នានា ជាពិសេសកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺកត្តារួមចំណែកតម្រង់ទិសការអភិវឌ្ឍរបស់ អ.ស.ជ ឱ្យឆ្លើយតបទៅនឹងការវិវត្តថ្មីៗក្នុងវិស័យសាធារណៈ។

២. ការពិចារណាលើវិធានការឆ្លើយតបយ៉ាងរហ័សលើការប្រែប្រួល ឬព្រឹត្តិការណ៍ថ្មីៗជាតិ និងអន្តរជាតិនៅក្នុងដំណាក់កាលរៀបចំ ក៏ដូចជាក្នុងពេលអនុវត្តផែនការយុទ្ធសាស្ត្រ។

៣. ការកំណត់យន្តការត្រឹមត្រូវ និងការចូលរួមយ៉ាងសកម្ម និងជាប្រចាំលើការងារត្រួតពិនិត្យតាមដាន និងវាយតម្លៃសូចនាករ និងផែនការសកម្មភាពដែលបានកំណត់ គឺជាសមាសធាតុយ៉ាងសំខាន់ក្នុងការសម្រេចបានជោគជ័យលើការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍។

៤. ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីសំណាក់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ព្រមទាំងភាគីពាក់ព័ន្ធផ្សេងទៀត។

- *បញ្ហាប្រឈម*

ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលគួរឱ្យកត់សម្គាល់ និងការខិតខំប្រឹងប្រែងយកចិត្តទុកដាក់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កន្លងមក នៅមានសកម្មភាពមួយចំនួនពុំទាន់បានអនុវត្តពេញលេញនៅឡើយ ដោយសារកត្តារាំងស្ទះមួយចំនួនដូចជា៖

១. កង្វះខាតហិរញ្ញវត្ថុ។

២. ធនធានមនុស្សនៅមានកម្រិត។

៣. ភាពអាចសម្រេចបាននៃយុទ្ធសាស្ត្រ និងសកម្មភាពដែលបានដាក់ចេញមួយចំនួនមានកម្រិតទាប។

៤. សកម្មភាពត្រួតពិនិត្យតាមដាន និងវាយតម្លៃមិនទាន់បានពេញលេញ។

៥. ការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩។

ពិនិត្យជារួមសម្រាប់ទិសដៅនៃការបន្តអភិវឌ្ឍ ភាពរាំងស្ទះជាគន្លឹះមួយចំនួនទាមទារនូវការបន្តដោះស្រាយ ហើយការអភិវឌ្ឍថ្មីៗក៏ជាតម្រូវការចាំបាច់ ដើម្បីឆ្លើយតបនឹងបម្រែបម្រួលសំខាន់ៗនៅក្នុងបរិបទនៃស្តង់ដារអន្តរជាតិសម្រាប់ការងារសវនកម្មសាធារណៈ ក៏ដូចជាការវិវត្តនៅក្នុងការងារកែទម្រង់វិស័យសាធារណៈ។ នៅក្នុងបរិការណ៍នេះ ការបន្តរៀបចំផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រគឺជាការងារអាទិភាពសម្រាប់ អ.ស.ជ ដើម្បីលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈសវនកម្ម និងការបន្តអភិវឌ្ឍស្ថាប័នក្នុងគោលបំណងធ្វើទំនើបកម្មការងារសវនកម្មឱ្យឆ្លើយតបនឹងនវានុវត្តន៍ថ្មីៗនៅក្នុងប្រទេស និងក្នុងបរិបទតំបន់ និងអន្តរជាតិ។ ជាមួយគ្នានេះ ការកំណត់នូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពគួរផ្តោតទៅលើភាពអាចសម្រេចបាននៃសកម្មភាពដែលជាតម្រូវការចាំបាច់ក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ និងស្ថាប័ន និងភាពអាចទ្រទ្រង់បាននៃថវិការបស់ អ.ស.ជ និងការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍។

# ផ្នែកទី ៣

# ក្របខណ្ឌរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដំណាក់កាលទី៤ (ឆ្នាំ២០២២ - ឆ្នាំ២០២៦)

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដំណាក់កាលទី៤ (ឆ្នាំ២០២២ - ឆ្នាំ២០២៦) នេះ ត្រូវបានរៀបចំឡើង ដើម្បីបន្តដំណើរការអភិវឌ្ឍរបស់ អ.ស.ជ ដោយពិចារណាលើមូលដ្ឋានគ្រឹះសំខាន់ៗ ដូចខាងក្រោម៖

(១) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមានការគ្រប់គ្រងចំណូល-ចំណាយ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information System - FMIS) និងគណនេយ្យភាពសមិទ្ធកម្ម និង

(២) ការវិវត្តក្នុងបរិបទតំបន់ និងអន្តរជាតិ រួមមានក្របខណ្ឌវាស់វែងការអនុវត្តរបស់ស្ថាប័នសវនកម្មកំពូល (Supreme Audit Institution Performance Measurement Framework - SAI PMF) របស់ INTOSAI សម្រាប់អភិបាលកិច្ចផ្ទៃក្នុងកាន់តែប្រសើរ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (Sustainable Development Goals - SDGs) ការរីកចម្រើននៃបច្ចេកវិទ្យាព័ត៌មាន កម្មវិធីអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈរបស់ INTOSAI, ASOSAI និង ASEANSAI និងការឆ្លើយតបទៅនឹងបញ្ហាដែលកំពុងកើតមាន និងអាចកើតឡើងជាយថាហេតុ ដូចជាជំងឺរាតត្បាតកូវីដ-១៩ និងបម្រែបម្រួលអាកាសធាតុជាដើម។

ការវិភាគតាមបែប SWOT ជាវិធីសាស្ត្រដ៏សំខាន់មួយសម្រាប់វិភាគលើចំណុចខ្លាំង (Strengths) ចំណុចខ្សោយ (Weaknesses) កាលានុវត្តភាព (Opportunities) និងបញ្ហាប្រឈម (Weaknesses) នៃស្ថានភាពបច្ចុប្បន្នរបស់ អ.ស.ជ។ ចំណុចខ្លាំង គឺជាកត្តាផ្ទៃក្នុងដែលធ្វើឱ្យ អ.ស.ជ មានដំណើរការទៅមុខ ចំណែកឯចំណុចខ្សោយ គឺជាកត្តាផ្ទៃក្នុងដែលរាំងស្ទះដល់ដំណើរការ និងការអភិវឌ្ឍរបស់ អ.ស.ជ។ ដូចនេះ ផែនការយុទ្ធសាស្ត្រត្រូវផ្តោតលើសកម្មភាពទាំងឡាយសំដៅពង្រឹងចំណុចខ្លាំង ដោយកាត់បន្ថយ ឬលុបបំបាត់ចំណុចខ្សោយ។

កាលានុវត្តភាព គឺជាកត្តាផ្ទៃក្រៅដែលផ្តល់ផលវិជ្ជមាន ចំណែកឯបញ្ហាប្រឈម គឺជាកត្តាផ្ទៃក្រៅដែលផ្តល់ផលអវិជ្ជមានដល់ អ.ស.ជ។ កត្តាទាំងពីរនេះអាចរងឥទ្ធិពលពីបរិយាកាសខាងក្រៅនៃអ.ស.ជ។ ការកំណត់បានកត្តាទាំងនេះធ្វើឱ្យងាយស្រួលដល់ការបង្កើតយុទ្ធសាស្ត្រ ដើម្បីទាញយកផលប្រយោជន៍ពីកាលានុវត្តភាព និងដោះស្រាយបញ្ហាប្រឈមទាំងនោះ។

តារាងខាងក្រោមនេះបង្ហាញពីការវិភាគតាមបែប SWOT របស់ អ.ស.ជ។

# ការវិភាគ SWOT របស់អាជ្ញាធរសវនកម្មជាតិ

## កត្តាផ្ទៃក្នុង

### ចំណុចខ្លាំង

- អ.ស.ជ បង្កើតដោយច្បាប់រៀបចំអង្គការ
- អ.ស.ជ មានឯករាជ្យភាពក្នុងកិច្ចប្រតិបត្តិការនៃការងារ
- អ.ស.ជ ជាស្ថាប័នសវនកម្មផ្ទៃក្រៅរាជរដ្ឋាភិបាល
- មន្ត្រីនៃអ.ស.ជទាំងអស់មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត
- មន្ត្រីនៃអ.ស.ជភាគច្រើនបានទទួលការបណ្តុះបណ្តាលនៅក្នុង និងក្រៅប្រទេស
- មន្ត្រីនៃអ.ស.ជមួយចំនួនមានសមត្ថភាពវិជ្ជាជីវៈខ្ពស់
- ថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការធានាគុណភាព និងការអភិវឌ្ឍ
- អ.ស.ជ មានស្តង់ដារ និងគោលការណ៍ណែនាំសវនកម្មសម្រាប់អនុវត្តការងារ
- អ.ស.ជ ជាសមាជិករបស់អង្គការ INTOSAI ASOSAI និងASEANSAI
- អ.ស.ជ បានចុះអនុស្សរណៈជាមួយស្ថាប័នសវនកម្មកំពូលមួយចំនួន។

### ចំណុចខ្សោយ

- ថវិការបស់ អ.ស.ជ នៅមានកម្រិត
- បទពិសោធន៍ និងជំនាញសវនកម្មនៅមានកម្រិតទៅតាមការវិវត្តថ្មីៗ
- សៀវភៅណែនាំសវនកម្មនៅមានកម្រិត
- ចំណេះដឹងភាសាបរទេសរបស់មន្ត្រីសវនកម្មនៅមានកម្រិត
- មិនមានជំនាញ និងធនធានគ្រប់គ្រាន់ក្នុងការប្រើប្រាស់ឧបករណ៍ និងបច្ចេកទេសជំនួយសវនកម្មតាមកម្មវិធីកុំព្យូទ័រ
- កង្វះខាតធនធានបង្កើតមូលដ្ឋានបច្ចេកវិទ្យាព័ត៌មាន ដើម្បីភ្ជាប់ជាមួយប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- កង្វះធនធាន ដើម្បីអភិវឌ្ឍប្រព័ន្ធបច្ចេក-វិទ្យាគាំទ្រការគ្រប់គ្រងការងារសវនកម្ម និងទំនាក់ទំនងរបស់ អ.ស.ជ។

## កត្តាផ្ទៃក្រៅ

### កាលានុវត្តភាព

- ជាសមាជិក INTOSAI ASOSAI និង ASEANSAI មានឱកាសទទួលយក និងផ្លាស់ប្តូរបទពិសោធន៍សវនកម្មជាមួយស្ថាប័នសវនកម្មកំពូល
- ការចាប់អារម្មណ៍ពីភាគីពាក់ព័ន្ធក្នុងការជួយពង្រឹងសមត្ថភាពរបស់ អ.ស.ជ
- ជួយរាជរដ្ឋាភិបាលគ្រប់គ្រងធនធានសាធារណៈឱ្យមានប្រសិទ្ធភាព
- មុខងារសវនកម្មផ្ទៃក្រៅរាជរដ្ឋាភិបាលដើរតួនាទីសំខាន់ក្នុងការរួមចំណែកពង្រឹងគណនេយ្យភាព និងអភិបាលកិច្ចល្អ
- ជួយភាគីពាក់ព័ន្ធសំខាន់ៗដែលប្រើប្រាស់របាយការណ៍សវនកម្មរបស់ អ.ស.ជ
- អ.ស.ជ អាចទទួលបានការគាំទ្រពីសំណាក់រដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលកាន់តែខ្លាំងឡើង។

### បញ្ហាប្រឈម

- មន្ត្រីដែលមានលក្ខណៈសម្បត្តិល្អៗអាចចាកចេញពី អ.ស.ជ ដោយសារផ្នែកឯកជនផ្តល់លាភការខ្ពស់ជាង
- ប្រព័ន្ធគណនេយ្យរបស់ក្រសួង និងស្ថាប័នសាធារណៈ ស្ថិតក្នុងដំណាក់កាលកែទម្រង់អាចនាំឱ្យការងារសវនកម្មមានលក្ខណៈស្មុគស្មាញ
- ភាគីពាក់ព័ន្ធនៅមិនទាន់យល់ជ្រួតជ្រាបច្បាស់លាស់អំពីមុខងារ និងតួនាទីរបស់ អ.ស.ជ
- កិច្ចសហការពីអង្គភាពរងសវនកម្មមួយចំនួននៅមានកម្រិត
- កិច្ចសហការរវាងសវនកម្មផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន និង អ.ស.ជ នៅមានកម្រិត
- នវានុវត្តន៍លឿនរហ័សនៃបច្ចេកវិទ្យាព័ត៌មាន
- ការរីករាលដាលនៃជំងឺកូវីដ-១៩។

# ផ្នែកទី ៤

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដំណាក់កាលទី៤

# (ឆ្នាំ២០២២ -ឆ្នាំ២០២៦)

## ៤.១. ចក្ខុវិស័យ

"ជួយរាជរដ្ឋាភិបាលគ្រប់គ្រងធនធានសាធារណៈប្រកបដោយភាពស័ក្តិសិទ្ធិ និងជួយលើការទទួលខុសត្រូវផ្នែកសាធារណៈ តាមរយៈការធ្វើសវនកម្មប្រកបដោយគុណភាព ទាន់ពេលវេលា និងជឿទុកចិត្ត"។

## ៤.២. បេសកកម្ម

អាជ្ញាធរសវនកម្មជាតិអនុវត្តមុខងារសវនកម្មផ្ទៃក្រៅចំពោះរាជរដ្ឋាភិបាលប្រកបដោយឯករាជ្យភាព និងសមត្ថភាពវិជ្ជាជីវៈខ្ពស់ ដើម្បីសម្រេចបាននូវលទ្ធផលសវនកម្មប្រកបដោយគុណភាព ទាន់ពេលវេលា និងជឿទុកចិត្ត ។

## ៤.៣. តម្លៃស្នូល



ការសម្រេចឱ្យបានតាមគោលដៅកំណត់នៅក្នុងចក្ខុវិស័យ និងបេសកកម្ម អ.ស.ជ ត្រូវមានធនធានសវនករដែលមានលក្ខណៈសម្បត្តិជាតម្លៃស្នូលចំនួន ៥។ តម្លៃស្នូលទាំងនេះនឹងជួយតម្រង់ទិសនៃការប្រតិបត្តិរបស់សវនករនៅក្នុងបរិបទនៃទំនាក់ទំនងការងារផ្ទៃក្នុងរបស់ អ.ស.ជ និងជាមួយភាគីពាក់ព័ន្ធ ។ តម្លៃស្នូលទាំង ៥ រួមមាន៖

| | |
|---|---|
| ឯករាជ្យភាព | ឯករាជ្យភាពនៃការមិនស្ថិតក្រោមសម្ពាធពីបរិយាកាសខាងក្រៅដែលធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តការងារវិជ្ជាជីវៈរបស់ខ្លួន។ សវនករទាំងអស់មានភាពឯករាជ្យក្នុងការបំពេញភារកិច្ចដោយត្រឹមត្រូវ និងមិនទទួលឥទ្ធិពលពីសង្គម ឬបរិយាកាសដែលនៅជុំវិញទាំងការចេញរបាយការណ៍ និងសេចក្តីសម្រេចផ្សេងៗ។ |
| សមត្ថភាពវិជ្ជាជីវៈ | សវនករមានជំនាញច្បាស់លាស់ក្នុងការបំពេញការងារសវនកម្មរបស់ខ្លួនប្រកបដោយវិជ្ជាជីវៈខ្ពស់ និងត្រូវបំពេញភារកិច្ចដោយស្របតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដារសវនកម្មអន្តរជាតិ។ អ.ស.ជ រក្សានូវឆន្ទៈយ៉ាងគត់មត់ក្នុងការបង្កើនជំនាញវិជ្ជាជីវៈជាបន្តបន្ទាប់សម្រាប់សវនករគ្រប់លំដាប់ថ្នាក់។ |
| សុចរិតភាព | សវនករប្រកាន់ខ្ជាប់នូវស្តង់ដារនៃភាពសុចរិតកម្រិតខ្ពស់មួយក្នុងការអនុវត្តវិជ្ជាជីវៈសវនកម្ម។ សវនករមានភាពស្មោះត្រង់ និងមិនលម្អៀងក្នុងការអនុវត្តការងារសវនកម្ម ប្រមូលព័ត៌មាន រាយការណ៍ពីសកម្មភាពការងារ ក៏ដូចជាការបង្ហាញនូវកំណត់សម្គាល់សវនកម្មប្រកបដោយសុចរិតភាព។ |
| តម្លាភាព | ដើម្បីបង្កើនការជឿទុកចិត្តពីសាធារណជន អ.ស.ជ រក្សានូវយន្តការទំនាក់ទំនងអំពីរបាយការណ៍សវនកម្មប្រកបដោយតម្លាភាព។ |
| ការទទួលខុសត្រូវ | សវនករមានការទទួលខុសត្រូវខ្ពស់ចំពោះភារកិច្ចដែលបានបំពេញនិងការទទួលបាននូវព័ត៌មានសម្រាប់ការងារសវនកម្ម ក៏ដូចជាការផ្តល់អនុសាសន៍សវនកម្ម និងធ្វើការតាមដានការអនុវត្តអនុសាសន៍ទាំងនោះ។ |

### ៤.៤. គោលបំណង

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងបេសកកម្មនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដំណាក់កាលទី៤ ចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៦ អាជ្ញាធរសវនកម្មជាតិបានកំណត់នូវគោលបំណងចំនួន ៣៖

គោលបំណងទី១: កសាង និងពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងគុណភាពសវនកម្ម ដើម្បីរួមចំណែកកាន់តែប្រសើរក្នុងការលើកកម្ពស់អភិបាលកិច្ចល្អក្នុងវិស័យសាធារណៈ

គោលបំណងទី២: លើកកម្ពស់ការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស ដើម្បីផ្តល់សេវាគាំទ្រកាន់តែប្រសើរដល់ការងារសវនកម្ម

គោលបំណងទី៣: ពង្រឹងទំនាក់ទំនងរវាងសវនកម្មផ្ទៃក្រៅ និងផ្ទៃក្នុង ព្រមទាំងភាគីពាក់ព័ន្ធ ដើម្បីបង្កើនស័ក្តិសិទ្ធិភាពនៃលទ្ធផលសវនកម្ម

**គោលបំណងទី១** «កសាង និងពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងគុណភាពសវនកម្ម ដើម្បីរួមចំណែកកាន់តែប្រសើរក្នុងការលើកកម្ពស់អភិបាលកិច្ចល្អក្នុងវិស័យសាធារណៈ»

ការកសាង និងពង្រឹងសមត្ថភាពវិជ្ជាជីវៈសវនកម្ម និងជំនាញពាក់ព័ន្ធ គឺជាអាទិភាពចម្បងសម្រាប់ អ.ស.ជ ដើម្បីបំពេញភារកិច្ចសវនកម្មផ្ទៃក្រៅចំពោះរាជរដ្ឋាភិបាលប្រកបដោយគុណភាព ជឿទុកចិត្ត និងទាន់ពេលវេលា។ ការបង្កើននូវប្រសិទ្ធភាពការងារសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ សវនកម្មលើកិច្ចប្រតិបត្តិការ និងសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ទាមទារនូវការអភិវឌ្ឍ និងការធ្វើឱ្យប្រសើរឡើងនូវកត្តាចាំបាច់មួយចំនួនដូចជា ការបណ្តុះបណ្តាល ការណែនាំនូវនីតិវិធី និងវិធីសាស្ត្រសវនកម្មថ្មី ប្រព័ន្ធត្រួតពិនិត្យ និងធានាគុណភាពសវនកម្ម និងការធ្វើបច្ចុប្បន្នភាពស្តង់ដារ និងសៀវភៅណែនាំសវនកម្ម។

ការត្រួតពិនិត្យ និងធានាគុណភាពសវនកម្ម គឺជាផ្នែកមួយយ៉ាងសំខាន់របស់ស្ថាប័នសវនកម្មកំពូលក្នុងការជួយធានានូវសង្គតិភាពនៃគុណភាពការងារសវនកម្មសម្រាប់គ្រប់ប្រភេទសវនម្មទាំងអស់។ ការងារនេះក៏ជួយផងដែរលើការកាត់បន្ថយហានិភ័យជាអប្បបរមានៃការប្រាសចាកពីស្តង់ដារ និងគោលការណ៍ណែនាំសវនកម្ម និងផ្តល់នូវវិធានការកែតម្រូវក្នុងកិច្ចប្រតិបត្តិការនៃការងារសវនកម្ម។ ដូចនេះ អ.ស.ជ រំពឹងថា ការបង្កើតនូវមុខងារត្រួតពិនិត្យ និងធានាគុណភាពសវនកម្មសម្រាប់គ្រប់ប្រភេទសវនកម្មទាំងអស់ទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្លួននឹងជួយលើកកម្ពស់គុណភាពការងារឱ្យកាន់តែប្រសើរឡើង។

លទ្ធផលសវនកម្ម គឺជាផលិតផលចុងក្រោយនៃការងារសវនកម្មផ្ទៃក្រៅរបស់ អ.ស.ជ ដែលរំពឹងថានឹងជួយបន្ថែមតម្លៃដល់កិច្ចប្រតិបត្តិការរបស់អង្គភាពរងសវនកម្ម និងជារួម គឺជួយដល់ការគ្រប់គ្រងធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព។ ស័ក្តិសិទ្ធិភាពនៃលទ្ធផលសវនកម្ម គឺអាស្រ័យលើការយកចិត្តទុកដាក់អនុវត្តអនុសាសន៍សវនកម្មពីសំណាក់អង្គភាព

វេងសវនកម្ម, ការតាមដានការអនុវត្តអនុសាសន៍សវនកម្មរបស់ អ.ស.ជ និងជាពិសេស ការចាត់វិធានការលើការអនុវត្តអនុសាសន៍សវនកម្មពីរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល។

អ.ស.ជ ត្រូវអនុវត្តកិច្ចការទាំងនេះដោយផ្សារភ្ជាប់ទៅនឹងក្របខណ្ឌកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលកំពុងបោះជំហានឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម និងដំណើរវិវត្តន៍ក្នុងបរិបទតំបន់ និងអន្តរជាតិ មានជាអាទិ៍ ផែនការយុទ្ធសាស្ត្ររបស់ INTOSAI, ASOSAI និង ASEANSAI ព្រមទាំងការកែប្រែសំខាន់ៗនៅក្នុងស្តង់ដារអន្តរជាតិ។

**គោលបំណងទី២** «លើកកម្ពស់ការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស ដើម្បីផ្តល់សេវាគាំទ្រកាន់តែប្រសើរដល់ការងារសវនកម្ម»

ដើម្បីអនុវត្តការងារសវនកម្មប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព អ.ស.ជ នឹងបន្តយកចិត្តទុកដាក់លើកកម្ពស់ការអភិវឌ្ឍស្ថាប័ន សំដៅគាំទ្រដល់ការងារសវនកម្ម និងការគ្រប់គ្រងធនធានមនុស្ស។ អ.ស.ជ មានតម្រូវការពង្រឹងបន្ថែមលើយន្តការគ្រប់គ្រងមន្ត្រី ដូចជាការគ្រប់គ្រងទិន្នន័យមន្ត្រី វិន័យការងារ ការវាយតម្លៃ និងលើកទឹកចិត្តជាដើម ដើម្បីបង្កើនប្រសិទ្ធភាពការងារ។

ការពង្រឹងគុណភាពនៃការរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា រួមចំណែកដល់ការធានាបាននូវការផ្តល់នូវបរិយាកាសបណ្តុះបណ្តាល និងសិក្ខាសាលាដែលជំរុញសិក្ខាកាមចូលរួមមានភាពសកម្ម និងអាចទទួលបានចំណេះដឹង ជំនាញវិជ្ជាជីវៈ ក៏ដូចជាការយល់ដឹងតាមការរំពឹងទុក។

ដើម្បីបន្តពង្រឹងសមត្ថភាពស្ថាប័នបន្ថែម អ.ស.ជ មានតម្រូវការលើបំពាក់បំប៉នជំនាញជាក់លាក់បន្ថែម និងបន្ថែមមុខងារជាក់លាក់ទាំងនោះទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្លួន ។ ជំនាញទាំងនោះ អាចរួមមាន នីតិកម្ម និងព័ត៌មានវិទ្យា។

អ.ស.ជ បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងកម្មវិធីកុំព្យូទ័រ និងថែទាំទិន្នន័យតាមប្រព័ន្ធព័ត៌មានវិទ្យាដែលជាកត្តាចាំបាច់ក្នុងសង្គមឌីជីថលក្នុងការគាំទ្រដល់ការងារសវនកម្ម។ ការងារនេះទាមទារឱ្យមន្ត្រីនៃ អ.ស.ជ បង្កើនសមត្ថភាពក្នុងការប្រើប្រាស់ឧបករណ៍ដែលមានស្រាប់ និងឧបករណ៍ដែលទើបតែអភិវឌ្ឍថ្មី ដើម្បីអនុវត្តការងាររបស់ អ.ស.ជ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្របខណ្ឌវាស់វែងការអនុវត្តរបស់ស្ថាប័នសវនកម្មកំពូល (Supreme Audit Institution Performance Measurement Framework - SAI PMF) នឹងត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់អភិវឌ្ឍស្ថាប័នតាមដំណាក់កាលនីមួយៗ ស្របតាមស្ថានភាពវិវត្តន៍ជាក់ស្តែងរបស់អ.ស.ជ។

**គោលបំណងទី៣** «ពង្រឹងទំនាក់ទំនងរវាងសវនកម្មផ្ទៃក្រៅ និងផ្ទៃក្នុង ព្រមទាំងភាគីពាក់ព័ន្ធ ដើម្បីបង្កើនស័ក្តិសិទ្ធិភាពនៃលទ្ធផលសវនកម្ម»

ការបង្កើនការយល់ដឹងអំពីតួនាទី និងភារកិច្ចរបស់អ.ស.ជ គឺពិតជាមានសារៈសំខាន់ណាស់ ពីព្រោះកិច្ចការនេះជួយឱ្យអង្គភាពរងសវនកម្ម និងភាគីពាក់ព័ន្ធផ្សេងៗទៀតយល់កាន់តែច្បាស់អំពីផលប្រយោជន៍នៃលទ្ធផលសវនកម្មក្នុងជួយបន្ថែមតម្លៃឱ្យសកម្មភាព និងអង្គភាពរបស់ពួកគេ ក៏ដូចជាការរួមចំណែកយ៉ាងខ្លាំងក្នុងការបង្កើនគណនេយ្យភាព និងតម្លាភាពនៃការគ្រប់គ្រងធនធានសាធារណៈ។ ដូចនេះ ដើម្បីបង្កើនស័ក្តិសិទ្ធិភាពនៃលទ្ធផលសវនកម្ម អ.ស.ជ នឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋសភា ព្រឹទ្ធសភា ក្រសួង ស្ថាប័ន សវនកម្មផ្ទៃក្នុង និងភាគីពាក់ព័ន្ធផ្សេងៗទៀតឱ្យកាន់តែប្រសើរឡើងជាលំដាប់។

អ.ស.ជ ជាសមាជិក INTOSAI, ASOSAI, និង ASEANSAI ដែលនេះជាឱកាសសម្រាប់មន្ត្រីទទួលបាននូវបទពិសោធន៍ និងឧត្តមានុវត្តន៍ពីស្ថាប័នសវនកម្មកំពូលដទៃទៀតក្នុងតំបន់ និងអន្តរជាតិ។ ដូចនេះ ការបន្តពង្រឹងទំនាក់ទំនងជាមួយស្ថាប័នអន្តរជាតិ និងស្ថាប័នសវនកម្មកំពូលនានាក្នុងតំបន់ និងអន្តរជាតិ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយសម្រាប់ អ.ស.ជ ក្នុងការទទួលបាននូវការទទួលស្គាល់ជាអន្តរជាតិកាន់តែប្រសើរឡើង ក៏ដូចជាឱកាសក្នុងការចូលរួមចែករំលែក និងការទទួលបានចំណេះដឹង បទពិសោធន៍ និងឧត្តមានុវត្តន៍អន្តរជាតិ ។

## ៤.៥. គោលដៅយុទ្ធសាស្ត្រ

គោលបំណងដែលបានដាក់ចេញខាងលើ មានការគាំទ្រពីគោលដៅយុទ្ធសាស្ត្រចំនួន ១៣។ គោលដៅយុទ្ធសាស្ត្របង្ហាញនូវតម្រាយផ្លូវគោលចម្បងៗក្នុងទិសដៅសម្រេចឱ្យបាននូវគោលបំណងដែលបានកំណត់ និងឈានទៅសម្រេចនូវចក្ខុវិស័យដែលបានដាក់ចេញ ដោយនឹងត្រូវរក្សាយ៉ាងខ្ជាប់ខ្ជួននូវបេសកកម្ម និងតម្លៃស្នូលរបស់សវនករ ក៏ដូចជារបស់ អ.ស.ជ ទាំងមូល។

គោលបំណងទី១: កសាង និងពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងគុណភាពសវនកម្ម ដើម្បីរួមចំណែកកាន់តែប្រសើរក្នុងការលើកកម្ពស់អភិបាលកិច្ចល្អក្នុងវិស័យសាធារណៈ

| គោលដៅយុទ្ធសាស្ត្រ | មូលដ្ឋានគោល | សូចនាករគន្លឹះ |
|---|---|---|
| ១.១. ការពង្រឹងសមត្ថភាព និងគុណភាពសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល(ISSAIs) | • ឆ្នាំ២០២១៖ មិនមានរបាយការណ៍វាយតម្លៃ<br>• ឆ្នាំ២០២៤៖ របាយការណ៍វាយតម្លៃត្រូវរៀបចំ (% ត្រូវកំណត់) | • មន្ត្រីនៃអ.ស.ជ ទាំងអស់ដែលបានទទួលការបណ្តុះបណ្តាលមានសមត្ថភាពធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដារ និងគោលការណ៍ណែនាំ<br>• ការងារសវនកម្មត្រូវបានពង្រឹងគុណភាព និងពង្រីកវិសាលភាពដោយអនុលោមតាមស្តង់ដារសវនកម្ម |
| ១.២ ការកសាង និងពង្រឹងសមត្ថភាព និងគុណភាពសវនកម្មលើកិច្ចប្រតិបត្តិការ ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល(ISSAIs) | • ឆ្នាំ២០២១៖ មិនមានរបាយការណ៍វាយតម្លៃ និងមិនទាន់មានគោលការណ៍ណែនាំ<br>• ឆ្នាំ២០២៤៖ របាយការណ៍វាយតម្លៃត្រូវរៀបចំ (% ត្រូវកំណត់) | • មន្ត្រីនៃអ.ស.ជ ទាំងអស់ដែលបានទទួលការបណ្តុះបណ្តាលមានសមត្ថភាពធ្វើសវនកម្មលើកិច្ចប្រតិបត្តិការស្របតាមស្តង់ដារ និងគោលការណ៍ណែនាំ<br>• ការងារសវនកម្មត្រូវបានពង្រឹងគុណភាព និងពង្រីកវិសាលភាពដោយអនុលោមតាមស្តង់ដារសវនកម្ម |
| ១.៣ ការពង្រឹងសមត្ថភាព និងគុណភាពសវនកម្មលើការអនុលោមតាមច្បាប់ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល(ISSAIs) | • ឆ្នាំ២០២១៖ មិនមានរបាយការណ៍វាយតម្លៃ និងមិនទាន់មានគោលការណ៍ណែនាំ<br>• ឆ្នាំ២០២៤៖ របាយការណ៍វាយតម្លៃត្រូវរៀបចំ (% ត្រូវកំណត់) | • មន្ត្រីនៃអ.ស.ជ ទាំងអស់ដែលបានទទួលការបណ្តុះបណ្តាលមានសមត្ថភាពធ្វើសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិស្របតាមស្តង់ដារ និងគោលការណ៍ណែនាំ<br>• ការងារសវនកម្មត្រូវបានពង្រឹងគុណភាព និងពង្រីកវិសាលភាពដោយអនុលោមតាមស្តង់ដារសវនកម្ម |

| គោលដៅយុទ្ធសាស្ត្រ | មូលដ្ឋានគោល | សូចនាករគន្លឹះ |
| --- | --- | --- |
| ១.៤ ការពង្រឹងសមត្ថភាព និងគុណភាពសវនកម្មលើប្រភេទសវនកម្មជាក់លាក់ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល(ISSAIs) | • ឆ្នាំ២០២១៖ កម្មវិធីសវនកម្មលើប្រធានបទជាក់លាក់ចំនួន ៣ (ចំណូលពន្ធដារ គយ និងចំណូល ចំណាយ ក្រុង ស្រុក ខណ្ឌ)<br>• ឆ្នាំ២០២១៖ ការអនុវត្តសវនកម្មលើចំណូលពន្ធដារ គយ និងចំណូល ចំណាយ ក្រុង ស្រុក ខណ្ឌ | • យ៉ាងហោចណាស់មានរបាយការណ៍សវនកម្មលើប្រធានបទជាក់លាក់ថ្មីចំនួន១ ត្រូវបានរៀបចំឡើងនៅរៀងរាល់២ឆ្នាំម្តង |
| ១.៥ ការបន្តអភិវឌ្ឍ និងពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងធានាគុណភាពសម្រាប់គ្រប់ប្រភេទសវនកម្ម | • ឆ្នាំ២០២១៖ មានក្រុមធានាគុណភាពសម្រាប់ប្រភេទសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | • ប្រព័ន្ធត្រួតពិនិត្យ និងធានាគុណភាពបានបង្កើត និងមានដំណើរការសម្រាប់គ្រប់ប្រភេទសវនកម្មទាំងអស់<br>• របាយការណ៍ត្រួតពិនិត្យបង្ហាញថាមានការកែលម្អគុណភាពសវនកម្ម |
| ១.៦ បង្កើនស័ក្តិសិទ្ធិភាពនៃការអនុវត្តអនុសាសន៍សវនកម្ម | • ឆ្នាំ២០២១៖ យន្តការសម្រាប់តាមដានអនុសាសន៍សវនកម្មដាច់ដោយឡែកពីគ្នា | • ឆ្នាំ២០២៤៖ យន្តការរួមសម្រាប់តាមដានការអនុវត្តអនុសាសន៍សវនកម្មត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាផ្លូវការ<br>• ឆ្នាំ២០២៥៖ ចំនួនអនុសាសន៍សវនកម្មដែលត្រូវបានអនុវត្តមានការកើនឡើង |
| ១.៧ ការធ្វើបច្ចុប្បន្នភាពស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យស្របតាមការវិវត្តនៃស្តង់ដារអន្តរជាតិ | •ឆ្នាំ២០២១៖ មិនទាន់បានធ្វើការវាយតម្លៃ និងធ្វើបច្ចុប្បន្នភាព | •ស្តង់ដារសវនកម្មសាធារណៈត្រូវបានធ្វើបច្ចុប្បន្នភាពស្របតាមគោលការណ៍ជាតិ និងអន្តរជាតិ |

គោលបំណងទី២: លើកកម្ពស់ការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស ដើម្បីផ្តល់សេវាគាំទ្រកាន់តែប្រសើរដល់ការងារសវនកម្ម

| គោលដៅយុទ្ធសាស្ត្រ | មូលដ្ឋានគោល | សូចនាករគន្លឹះ |
|---|---|---|
| ២.១. ពង្រឹងការគ្រប់គ្រងធនធានមនុស្ស | • ឆ្នាំ២០២១៖ សៀវភៅណែនាំស្តីពីការគ្រប់គ្រងធនធានមនុស្សមិនទាន់ត្រូវបានអនុវត្តពេញលេញ | • ការគ្រប់គ្រងមន្ត្រីមានភាពល្អប្រសើរ<br>• មន្ត្រីអ.ស.ជ ប្រកាន់ខ្ជាប់វិន័យការងារ និងទទួលបានការវាយតម្លៃ និងលើកទឹកចិត្ត |
| ២.២. ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ដើម្បីពង្រឹងជំនាញវិជ្ជាជីវៈសវនកម្ម និងជំនាញពាក់ព័ន្ធ | • ឆ្នាំ២០២១៖ សៀវភៅណែនាំស្តីពីការបណ្តុះបណ្តាលមិនទាន់ត្រូវបានអនុវត្តពេញលេញ<br>• ឆ្នាំ២០២១៖ ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការបណ្តុះបណ្តាលមិនទាន់គ្រប់គ្រាន់ | • ឆ្នាំ២០២៣៖ ផែនការបណ្តុះបណ្តាលប្រចាំឆ្នាំត្រូវបានរៀបចំដោយផ្អែកតាមសៀវភៅណែនាំស្តីពីការបណ្តុះបណ្តាល តម្រូវការជាក់ស្តែង និងផ្សារភ្ជាប់ទៅនឹងគោលបំណងផ្សេងទៀតនៅក្នុងផែនការយុទ្ធសាស្ត្រ<br>• ឆ្នាំ២០២៤៖ របាយការណ៍វាយតម្លៃលើការបណ្តុះបណ្តាលទាំងឡាយត្រូវបានរៀបចំ និងមានបង្ហាញអំពីស្ថានភាពនៃភាពស័ក្តិសិទ្ធិរបស់ផែនការបណ្តុះបណ្តាល |
| ២.៣. បន្តអភិវឌ្ឍ និងពង្រឹងសេវាគាំទ្រដល់ការងារសវនកម្ម | • ឆ្នាំ២០២១៖ ការអភិវឌ្ឍ ការស្តារ និងការថែទាំប្រព័ន្ធព័ត៌មានវិទ្យាចាំបាច់នានា ដើម្បីគាំទ្រដល់ការងារសវនកម្មនៅមានកម្រិត | • ឆ្នាំ២០២៦៖ គ្រឿងបរិក្ខាប្រព័ន្ធព័ត៌មានវិទ្យានិងកម្មវិធីកុំព្យូទ័រដែលមានស្រាប់ និងតម្រូវការថ្មី ត្រូវបានបំពាក់ និងតម្លើង ស្របតាមតម្រូវការដែលបានគ្រោងក្នុងឆ្នាំ២០២៣ |
| ២.៤. បង្កើនការយល់ដឹង និងការអនុវត្តក្របខណ្ឌវាស់វែងការអនុវត្តរបស់ស្ថាប័នសវនកម្មកំពូល (SAI PMF) ក្នុងបរិបទរបស់ អ.ស.ជ | • ឆ្នាំ២០២១៖ ការយល់ដឹងនិងការអនុវត្ត SAI PMF ក្នុងបរិបថ អ.ស.ជ នៅមិនទាន់បានទូលំទូលាយ | • ឆ្នាំ២០២៣៖ ការយល់ដឹងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអ.ស.ជ អំពី SAI PMF<br>• ឆ្នាំ២០២៥៖ SAI PMF ត្រូវបានប្រើប្រាស់ និងវាយតម្លៃ ដើម្បីមានមូលដ្ឋានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍បន្ទាប់ឱ្យកាន់តែគ្រប់ជ្រុងជ្រោយ |

គោលបំណងទី៣: ពង្រឹងទំនាក់ទំនងរវាងសវនកម្មផ្ទៃក្រៅ និងផ្ទៃក្នុង ព្រមទាំងភាគីពាក់ព័ន្ធ ដើម្បីបង្កើនស័ក្តិសិទ្ធិភាពនៃលទ្ធផលសវនកម្ម

| គោលដៅជាយុទ្ធសាស្ត្រ | មូលដ្ឋានគោល | សូចនាករគន្លឹះ |
| --- | --- | --- |
| ៣.១ លើកកម្ពស់ការយល់ដឹង និងទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធខាងក្រៅអំពីមុខងារសវនកម្មផ្ទៃក្រៅ | • ឆ្នាំ២០២១៖ ការយល់ដឹង និងកិច្ចសហការរបស់ភាគីពាក់ព័ន្ធខាងក្រៅអំពីមុខងារសវនកម្មផ្ទៃក្រៅនៅមានកម្រិត | • ភាពប្រសើរឡើងនៃទំនាក់ទំនងរវាងសវនកម្មផ្ទៃក្រៅ និងផ្ទៃក្នុង<br>• ភាគីពាក់ព័ន្ធខាងក្រៅទទួលបានការយល់ដឹងកាន់តែប្រសើរអំពីតួនាទីសវនកម្មផ្ទៃក្រៅ |
| ៣.២ ពង្រឹង និងពង្រីកទំនាក់ទំនងជាមួយស្ថាប័នក្នុងតំបន់ និងអន្តរជាតិ ដើម្បីរួមចំណែកអភិវឌ្ឍន៍វិជ្ជាជីវៈសវនកម្មក្នុងបរិបទអន្តរជាតិ | • ឆ្នាំ២០២១៖ ភាគរយនៃមន្ត្រី អ.ស.ជ ដែលបានចូលរួមវគ្គបណ្តុះបណ្តាល ឬព្រឹត្តិការណ៍នានានៅបរទេសបានចែករំលែកបទពិសោធន៍ (កំណត់ពេលក្រោយ) | • ឆ្នាំ២០២៦៖ អ.ស.ជ បានចូលរួម និងមានទំនាក់ទំនងកាន់តែសកម្មជាមួយស្ថាប័នសវនកម្មកំពូល និងស្ថាប័នក្នុងតំបន់ និងអន្តរជាតិ |

## ៤.៦. ផែនការសកម្មភាព

ផែនការសកម្មភាពសម្រាប់គាំទ្រដល់ការសម្រេចជោគជ័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ អ.ស.ជ ដំណាក់កាលទី៤ ត្រូវបានកំណត់ជាពីរផ្នែក រួមមាន ផ្នែកទី១ គឺជាផែនការសកម្មភាពចម្បងៗសម្រាប់ការអនុវត្តពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៦ (ដូចមានបង្ហាញជូនខាងក្រោម) និងផ្នែកទី២ គឺជាផែនការសកម្មភាពប្រចាំឆ្នាំ (ឧបសម្ព័ន្ធទី១ ទម្រង់គំរូនៃផែនការសកម្មភាពប្រចាំឆ្នាំ)។

ផែនការសកម្មភាព ៥ឆ្នាំ (ឆ្នាំ២០២២ ដល់ឆ្នាំ២០២៦) គឺជាមូលដ្ឋានសម្រាប់ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីសម្រេចបាននូវគោលបំណង និងគោលដៅយុទ្ធសាស្ត្រដែលបានកំណត់។ ផែនការសកម្មភាពប្រចាំឆ្នាំត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីសកម្មភាពជាក់លាក់ ដោយបញ្ជាក់អំពីលទ្ធផលរំពឹងទុក ការទទួលខុសត្រូវ និងក្របខណ្ឌពេលវេលាដែលត្រូវអនុវត្ត។ ផែនការសកម្មភាពប្រចាំឆ្នាំនេះនឹងត្រូវក្លាយជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្រ។ ផែនការសកម្មភាពប្រចាំឆ្នាំនឹងត្រូវរៀបចំដោយនាយកដ្ឋាន និងក្រុមការងារទទួលបន្ទុកអនុវត្តសកម្មភាពឱ្យបានចប់រួចរាល់ត្រឹមខែមករានៃឆ្នាំបន្ទាប់ ដើម្បីដាក់ជូនក្រុមការងារត្រួតពិនិត្យ និងផ្តល់យោបល់លើការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ដើម្បីពិនិត្យ និងផ្តល់យោបល់។ ផែនការនេះនឹងត្រូវសម្រេចដោយអគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ។ ចំពោះផ្នែកហិរញ្ញវត្ថុចំណាយសម្រាប់ទ្រទ្រង់ការអនុវត្តផែនការយុទ្ធសាស្ត្រក៏នឹងត្រូវសម្រេចដោយអគ្គសវនករ។ គម្រោងថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ មានលម្អិតក្នុងឧបសម្ព័ន្ធទី២។

## ផែនការសកម្មភាព ៥ឆ្នាំ (ឆ្នាំ២០២២ - ២០២៦)

**គោលបំណងទី១**

**«កសាង និងពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងគុណភាពសវនកម្ម ដើម្បីរួមចំណែកកាន់តែប្រសើរក្នុងការលើកកម្ពស់អភិបាលកិច្ចល្អក្នុងវិស័យសាធារណៈ»**

| គោលដៅយុទ្ធសាស្ត្រ<br>១.១. ការពង្រឹងសមត្ថភាព និងគុណភាពសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល(ISSAIs) | សូចនាករគន្លឹះ:<br>- មន្ត្រីនៃអ.ស.ជ ទាំងអស់ដែលបានទទួលការបណ្តុះបណ្តាល មានសមត្ថភាពធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដារ និងគោលការណ៍ណែនាំ<br>- ការងារសវនកម្មត្រូវបានពង្រឹងគុណភាព និងពង្រីកវិសាលភាព ដោយអនុលោមតាមស្តង់ដារសវនកម្ម |
|---|---|

| សកម្មភាពចម្បង | សូចនាករ | ក្របខណ្ឌពេលវេលា | ប្រភពធនធាន | ការទទួលខុសត្រូវ |
|---|---|---|---|---|
| ១.១.១ ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលជំនាញសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | • គ្រូបង្គោល និងមន្ត្រីនៃអ.ស.ជ លើរបាយការណ៍ហិរញ្ញវត្ថុបានទទួលការបណ្តុះបណ្តាល និងត្រូវបានវាយតម្លៃ | ២០២២ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.បច្ចេកទេស<br>ក្រុមគ្រូបង្គោល |
| ១.១.២ ធ្វើឱ្យប្រសើរឡើងនូវគុណភាពសវនកម្ម និងបង្កើនចំនួនការងារសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាមសៀវភៅណែនាំទូទៅលើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | • ចំនួនការងារសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុកើនឡើងរៀងរាល់ឆ្នាំ (ធៀបនឹងផែនការសវនកម្មប្រចាំឆ្នាំ២០២២)<br>• កម្រិតអនុលោមភាពនៃការអនុវត្តគោលការណ៍ណែនាំសវនកម្ម ត្រូវបានបង្កើន | ២០២២ - ២០២៦ | អ.ស.ជ | ន.សវនកម្មទី ១<br>ន.សវនកម្មទី ២<br>ន.សវនកម្មទី ៣<br>ក្រុមការងារធានាគុណភាព |
| ១.១.៣ ធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីឱ្យស្របតាមបរិបទនៃបម្រែបម្រួលស្តង់ដារអន្តរជាតិ និងតម្រូវការជាក់ស្តែងរបស់ អ.ស.ជ | • ក្រុមការងារត្រូវបានបង្កើតឡើងដើម្បីសិក្សាអំពីលទ្ធភាពនៃការធ្វើបច្ចុប្បន្នសៀវភៅណែនាំ<br>• សៀវភៅណែនាំសវនកម្មត្រូវបានធ្វើបច្ចុប្បន្នភាព តាមការចាំបាច់ | ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.សវនកម្មទី ១<br>ក្រុមគ្រូបង្គោល |

| គោលដៅយុទ្ធសាស្ត្រ<br>១.២. ការកសាង និងពង្រឹងសមត្ថភាព និងគុណភាពសវនកម្មលើកិច្ចប្រតិបត្តិការ ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល(ISSAIs) | សូចនាករគន្លឹះ<br>- មន្ត្រីនៃអ.ស.ជ ទាំងអស់ដែលបានទទួលការបណ្តុះបណ្តាល មានសមត្ថភាពធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ ស្របតាមស្តង់ដារ និងគោលការណ៍ណែនាំ<br>- ការងារសវនកម្មត្រូវបានពង្រឹងគុណភាព និងពង្រីកវិសាលភាព ដោយអនុលោមតាមស្តង់ដារសវនកម្ម |
|---|---|

| សកម្មភាពចម្បង | សូចនាករ | ក្របខណ្ឌពេលវេលា | ប្រភពធនធាន | ការទទួលខុសត្រូវ |
|---|---|---|---|---|
| ១.២.១ ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលជំនាញសវនកម្មលើកិច្ចប្រតិបត្តិការ | • គ្រូបង្គោល និងមន្ត្រីនៃអ.ស.ជ លើកិច្ចប្រតិបត្តិការបានទទួលការបណ្តុះបណ្តាល និងត្រូវបានវាយតម្លៃ | ២០២២ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.បច្ចេកទេស<br>ក្រុមគ្រូបង្គោល |
| ១.២.២ ធ្វើឱ្យប្រសើរឡើងនូវគុណភាពសវនកម្ម និងបង្កើនចំនួនការងារសវនកម្មលើកិច្ចប្រតិបត្តិការ ដោយអនុលោមតាមសៀវភៅណែនាំសវនកម្មលើកិច្ចប្រតិបត្តិការ | • ការងារសវនកម្មលើកិច្ចប្រតិបត្តិការចំនួន០៤ យ៉ាងតិចត្រូវបានរៀបចំឡើងរៀងរាល់ឆ្នាំ<br>• កម្រិតអនុលោមភាពនៃការអនុវត្តគោលការណ៍ណែនាំសវនកម្ម ត្រូវបានបង្កើន | ២០២២ - ២០២៦ | អ.ស.ជ | ន.សវនកម្មទី ១<br>ន.សវនកម្មទី ២<br>ន.សវនកម្មទី ៣<br>ក្រុមការងារធានាគុណភាព |
| ១.២.៣ ធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំសវនកម្មលើកិច្ចប្រតិបត្តិការ ដើម្បីឱ្យស្របតាមបរិបទនៃបម្រែបម្រួលស្តង់ដារអន្តរជាតិ និងតម្រូវការជាក់ស្តែងរបស់ អ.ស.ជ | • ក្រុមការងារត្រូវបានបង្កើតឡើងដើម្បីសិក្សាអំពីលទ្ធភាពនៃការធ្វើបច្ចុប្បន្នសៀវភៅណែនាំ<br>• សៀវភៅណែនាំសវនកម្មត្រូវបានធ្វើបច្ចុប្បន្នភាព តាមការចាំបាច់ | ២០២៥ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.សវនកម្មទី ១<br>ន.សវនកម្មទី ២<br>ន.សវនកម្មទី ៣<br>ន.បច្ចេកទេស<br>ន.អន្តរជាតិ<br>ក្រុមគ្រូបង្គោល |

| គោលដៅយុទ្ធសាស្ត្រ<br>១.៣. ការពង្រឹងសមត្ថភាព និងគុណភាពសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល(ISSAIs) | សូចនាករគន្លឹះ:<br>- មន្ត្រីនៃអ.ស.ជ ទាំងអស់ដែលបានទទួលការបណ្តុះបណ្តាល មានសមត្ថភាពធ្វើសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិស្របតាមស្តង់ដារ និងគោលការណ៍ណែនាំ<br>- ការងារសវនកម្មត្រូវបានពង្រឹងគុណភាព និងពង្រីកវិសាលភាព ដោយអនុលោមតាមស្តង់ដារសវនកម្ម | | | |
|---|---|---|---|---|
| **សកម្មភាពចម្បង** | **សូចនាករ** | **ក្របខណ្ឌពេលវេលា** | **ប្រភពធនធាន** | **ការទទួលខុសត្រូវ** |
| ១.៣.១ ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលជំនាញសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ | • គ្រូបង្គោល និងមន្ត្រីនៃអ.ស.ជ លើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ បានទទួលការបណ្តុះបណ្តាល និងត្រូវបានវាយតម្លៃ | ២០២២ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.បច្ចេកទេស |
| ១.៣.២ ធ្វើឱ្យប្រសើរឡើងនូវគុណភាពសវនកម្ម និងបង្កើនចំនួនការងារសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ដោយអនុលោមតាមសៀវភៅណែនាំទូទៅលើសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ | • ចំនួនការងារសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ កើនឡើងរៀងរាល់ឆ្នាំ (ធៀបនឹងផែនការសវនកម្មប្រចាំឆ្នាំ២០២២)<br>• កម្រិតអនុលោមភាពនៃការអនុវត្តគោលការណ៍ណែនាំសវនកម្ម ត្រូវបានបង្កើន | ២០២២ - ២០២៦ | អ.ស.ជ | ន.សវនកម្មទី ២<br>ន.សវនកម្មទី ៣ |
| ១.៣.៣ ធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំទូទៅលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ដើម្បីឱ្យស្របតាមបរិបទនៃបម្រែបម្រួលស្តង់ដារអន្តរជាតិ និងតម្រូវការជាក់ស្តែងរបស់ អ.ស.ជ | • ក្រុមការងារត្រូវបានបង្កើតឡើងដើម្បីសិក្សាអំពីលទ្ធភាពនៃការធ្វើបច្ចុប្បន្នសៀវភៅណែនាំ<br>• សៀវភៅណែនាំសវនកម្មត្រូវបានធ្វើបច្ចុប្បន្នភាព តាមការចាំបាច់ | ២០២៥ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.សវនកម្មទី ៣<br>ក្រុមគ្រូបង្គោល |

| គោលដៅយុទ្ធសាស្ត្រ<br>១.៤. ការពង្រឹងសមត្ថភាព និងគុណភាពសវនកម្មលើប្រភេទសវនកម្មជាក់លាក់ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល(ISSAIs) | សូចនាករគន្លឹះ:<br>• យ៉ាងហោចណាស់មានរបាយការណ៍សវនកម្មលើប្រធានបទជាក់លាក់ថ្មីចំនួន១ ត្រូវបានរៀបចំឡើងនៅរៀងរាល់២ឆ្នាំម្តង |
|---|---|

| សកម្មភាពចម្បង | សូចនាករ | ក្របខណ្ឌពេលវេលា | ប្រភពធនធាន | ការទទួលខុសត្រូវ |
|---|---|---|---|---|
| ១.៤.១ ពង្រឹងសមត្ថភាពសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យា | • សៀវភៅណែនាំសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យា ត្រូវបានរៀបចំ និងអនុម័ត<br>• សវនករបានទទួលនូវការបំពាក់បំប៉នជំនាញថ្មីនេះ តាមរយៈការបណ្តុះបណ្តាល និងការធ្វើសវនកម្មសាកល្បង | ២០២៣ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.សវនកម្មទី១<br>ន.បច្ចេកទេស |
| ១.៤.២ ពង្រឹងសមត្ថភាពសវនកម្មលើព័ត៌មានសមិទ្ធកម្ម | • ឯកសារគោលការណ៍ណែនាំសម្រាប់សវនកម្មលើព័ត៌មានសមិទ្ធកម្មត្រូវបានរៀបចំ<br>• សវនករបានទទួលនូវការបំពាក់បំប៉នជំនាញថ្មីនេះ តាមរយៈការបណ្តុះបណ្តាល និងការធ្វើសវនកម្មសាកល្បង | ២០២៣ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.សវនកម្មទី១<br>ន.បច្ចេកទេស |
| ១.៤.៣ ពង្រឹងសមត្ថភាពសវនកម្មលើគោលដៅអភិវឌ្ឍន៍ចីរភាព (Sustainable Development Goals-SDGs) | • សៀវភៅណែនាំសវនកម្មលើគោលដៅអភិវឌ្ឍន៍ចីរភាព ត្រូវបានរៀបចំ និងអនុម័ត<br>• សវនករបានទទួលនូវការបំពាក់បំប៉នជំនាញថ្មីនេះ តាមរយៈការបណ្តុះបណ្តាល និងការធ្វើសវនកម្មសាកល្បង។<br>(បច្ចុប្បន្នបណ្តុះបណ្តាលបាន៥រូប) | ២០២៣ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.សវនកម្មទី១<br>ន.បច្ចេកទេស |

| សកម្មភាពចម្បង | សូចនាករ | ក្របខណ្ឌពេលវេលា | ប្រភពធនធាន | ការទទួលខុសត្រូវ |
|---|---|---|---|---|
| ១.៤.៤ ពង្រឹងសមត្ថភាពសវនកម្មលើការគ្រប់គ្រង និងប្រើប្រាស់ថវិកាឃុំ-សង្កាត់ | • កម្មវិធីសវនកម្មលើលើការគ្រប់គ្រង និងប្រើប្រាស់ថវិកាឃុំ-សង្កាត់ត្រូវបានរៀបចំ និងអនុម័ត<br>• សវនករបានទទួលនូវការបំពាក់បំប៉នជំនាញថ្មីនេះ តាមរយៈការបណ្តុះបណ្តាល<br>• យ៉ាងហោចណាស់ មានឃុំ (ស្ថិតក្នុងទីប្រជុំជន និងទីដាច់ស្រយាល) ចំនួន ៤ និង មានសង្កាត់នៃរាជធានីភ្នំពេញចំនួន ៤ ត្រូវបានការធ្វើសវនកម្មរៀងរាល់ឆ្នាំ។ | ២០២៣ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.សវនកម្មទី២<br>ន.បច្ចេកទេស |
| ១.៤.៥ បច្ចុប្បន្នភាពលើគោលការណ៍សវនកម្មលើប្រភេទដាក់លាក់ដែលមានស្រាប់ | • យ៉ាងហោចណាស់មានសៀវភៅណែនាំសវនកម្មលើប្រភេទដាក់លាក់ដែលមានស្រាប់ចំនួន២ ត្រូវបានធ្វើបច្ចុប្បន្នភាព<br>• សវនករបានទទួលនូវការបំពាក់បំប៉នតាមរយៈការបណ្តុះបណ្តាល និងការធ្វើសវនកម្ម | ២០២៥ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.សវនកម្មទី១<br>ន.សវនកម្មទី២<br>ន.សវនកម្មទី៣ |
| **<u>គោលដៅយុទ្ធសាស្ត្រ</u>**<br>**១.៥ បន្តអភិវឌ្ឍ និងពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងធានាគុណភាពសម្រាប់គ្រប់ប្រភេទសវនកម្ម** | | **សូចនាករគន្លឹះ:**<br>• ប្រព័ន្ធត្រួតពិនិត្យ និងធានាគុណភាពបានបង្កើត និងមានដំណើរការសម្រាប់គ្រប់ប្រភេទសវនកម្មទាំងអស់<br>• របាយការណ៍ត្រួតពិនិត្យបង្ហាញថាមានការកែលម្អគុណភាពសវនកម្ម | | |
| ១.៥.១ បង្កើតប្រព័ន្ធ និងមុខងារធានាគុណភាពសវនកម្មសម្រាប់គ្រប់ប្រភេទសវនកម្ម | • ប្រព័ន្ធ និងមុខងារធានាគុណភាពសវនកម្មត្រូវបានបង្កើតក្នុងរចនាសម្ព័ន្ធគ្រប់គ្រងសម្រាប់គ្រប់ប្រភេទសវនកម្ម | ២០២៣ - ២០២៦ | អ.ស.ជ | ក្រុមការងារ |
| ១.៥.២ ពង្រឹងការអនុវត្តការធានាគុណភាពសម្រាប់គ្រប់ប្រភេទសវនកម្ម | • សមត្ថភាពរបស់ក្រុមការងារធានាគុណភាពត្រូវបានពង្រឹង<br>• របាយការណ៍ស្តីពីការធានាគុណភាពសវនកម្មបង្ហាញអំពីភាពប្រសើរឡើងនៃគុណភាពការងារសវនកម្ម | ២០២៣ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ក្រុមការងារ |

| សកម្មភាពចម្បង | សូចនាករ | ក្របខណ្ឌពេលវេលា | ប្រភពធនធាន | ការទទួលខុសត្រូវ |
|---|---|---|---|---|
| ១.៥.៣ ពង្រឹងការអនុវត្តនីតិវិធីលើការត្រួតពិនិត្យគុណភាពសវនកម្ម (QC) | • នីតិវិធី និងបទដ្ឋានស្តង់ដាររួមសម្រាប់ការត្រួតពិនិត្យគុណភាពសវនកម្មដែលបានកំណត់ និងទម្រង់គំរូដែលបានបង្កើតត្រូវបានប្រើប្រាស់ | ២០២៣ - ២០២៤ | អ.ស.ជ | ន.សវនកម្មទី១<br>ន.សវនកម្មទី២<br>ន.សវនកម្មទី៣ |
| **<u>គោលដៅយុទ្ធសាស្ត្រ</u>**<br>**១.៦ បង្កើនស័ក្តិសិទ្ធិភាពនៃការអនុវត្តអនុសាសន៍សវនកម្ម** | **សូចនាករគន្លឹះ:**<br>• ឆ្នាំ២០២៤៖ យន្តការរួមសម្រាប់តាមដានការអនុវត្តអនុសាសន៍សវនកម្មត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាផ្លូវការ<br>• ឆ្នាំ២០២៥៖ ចំនួនអនុសាសន៍សវនកម្មដែលត្រូវបានអនុវត្តមានការកើនឡើង | | | |
| ១.៦.១ បង្កើតគោលការណ៍រួម/សេចក្តីណែនាំស្តីពីការអនុវត្តការតាមដានអនុសាសន៍ | • គោលនយោបាយរួមស្តីពីការអនុវត្តការតាមដានអនុសាសន៍សវនកម្មត្រូវបានបង្កើតឡើង និងដាក់ឱ្យអនុវត្ត | ២០២៣ - ២០២៤ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.សវនកម្មទី១<br>ន.សវនកម្មទី២<br>ន.សវនកម្មទី៣<br>ក្រុមការងារ |
| ១.៦.២ បង្កើតប្រព័ន្ធសម្រាប់គ្រប់គ្រង និងតាមដានការអនុវត្តអនុសាសន៍សវនកម្ម | • ប្រព័ន្ធគ្រប់គ្រងការតាមដានអនុសាសន៍សវនកម្មតាមកម្មវិធីកំព្យូទ័រត្រូវបានតម្លើង ដាក់ឱ្យដំណើរការ និងថែទាំ | ២០២៤ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.សវនកម្មទី១<br>ន.សវនកម្មទី២<br>ន.សវនកម្មទី៣<br>ក្រុមការងារ |
| ១.៦.៣ ពន្លឿនការងាររៀបចំរបាយការណ៍សវនកម្មប្រចាំឆ្នាំជាសាធារណៈឱ្យបានទាន់ពេលវេលា | • របាយការណ៍សវនកម្មប្រចាំឆ្នាំត្រូវបានផ្សព្វផ្សាយជាសាធារណៈបានតាមពេលកំណត់ | ២០២២ - ២០២៦ | អ.ស.ជ | ន.សវនកម្មទី១<br>ន.សវនកម្មទី២<br>ន.សវនកម្មទី៣<br>ក្រុមការងារ |

| គោលដៅយុទ្ធសាស្រ្ត<br>១.៧ ការធ្វើបច្ចុប្បន្នភាពស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យស្របតាមការវិវត្ត នៃស្តង់ដារអន្តរជាតិ | | **សូចនាករគន្លឹះ:**<br>• ស្តង់ដារសវនកម្មសាធារណៈត្រូវបានធ្វើបច្ចុប្បន្នភាពស្របតាមគោលការណ៍ជាតិ និងអន្តរជាតិ | | |
|---|---|---|---|---|
| **សកម្មភាពចម្បង** | **សូចនាករ** | **ក្របខណ្ឌពេលវេលា** | **ប្រភពធនធាន** | **ការទទួលខុសត្រូវ** |
| ១.៧.១ សិក្សា និងតាមដានអំពីការវិវត្តនៃស្តង់ដារអន្តរជាតិ ដើម្បីមានមូលដ្ឋានធ្វើបច្ចុប្បន្នភាព ស្តងដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា | • ក្រុមការងារត្រូវបានបង្កើតឡើងដើម្បីសិក្សាអំពីលទ្ធភាពនៃការធ្វើបច្ចុប្បន្នស្តង់ដារសវនកម្មសាធារណៈ<br>• ស្តង់ដារសវនកម្មសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានធ្វើបច្ចុប្បន្នភាព តាមការចាំបាច់ | ២០២៤- ២០២៦ | អ.ស.ជ | ន.សវនកម្មទី១<br>ន.សវនកម្មទី២<br>ន.សវនកម្មទី៣<br>ក្រុមការងារ |

## គោលបំណងទី២

## «លើកកម្ពស់ការអនុវត្តរបស់ស្ថាប័ន និងធនធានមនុស្ស ដើម្បីពង្រឹងសេវាគាំទ្រដល់ការងារសវនកម្ម

| គោលដៅយុទ្ធសាស្ត្រ | សូចនាករគន្លឹះ: |
| --- | --- |
| ២.១. ពង្រឹងការគ្រប់គ្រងធនធានមនុស្ស | • ការគ្រប់គ្រងមន្ត្រីមានភាពល្អប្រសើរ<br>• មន្ត្រីអ.ស.ជ ប្រកាន់ខ្ជាប់វិន័យការងារ និងទទួលបានការវាយតម្លៃ និងលើកទឹកចិត្ត |

| សកម្មភាពចម្បង | សូចនាករ | ក្របខណ្ឌពេលវេលា | ប្រភពធនធាន | ការទទួលខុសត្រូវ |
| --- | --- | --- | --- | --- |
| ២.១.១ ពង្រឹងការអនុវត្តសៀវភៅណែនាំស្តីពីការគ្រប់គ្រងធនធានមនុស្ស | • គោលនយោបាយតម្លើងថ្នាក់ វត្តមាន និងវិន័យត្រូវបានអនុវត្តស្របតាមសៀវភៅណែនាំស្តីពីការគ្រប់គ្រងធនធានមនុស្ស | ២០២២ - ២០២៦ | អ.ស.ជ | ន.រដ្ឋបាល &ហិរ.<br>ន.ពាក់ព័ន្ធ |
| ២.១.២ រៀបចំតម្លើងប្រព័ន្ធរក្សាទុក និងគ្រប់គ្រងទិន្នន័យរបស់មន្ត្រី អ.ស.ជ | • ប្រព័ន្ធរក្សាទុក និងការគ្រប់គ្រងទិន្នន័យតាមកម្មវិធីកំព្យូទ័រត្រូវបានបង្កើត ដាក់ឱ្យប្រើប្រាស់ និងថែទាំ | ២០២៣ - ២០២៤ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.រដ្ឋបាល &ហិរ.<br>ន.បច្ចេកទេស |

| គោលដៅយុទ្ធសាស្ត្រ<br>២.២. ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ដើម្បីពង្រឹងជំនាញវិជ្ជាជីវៈសវនកម្ម និងជំនាញពាក់ព័ន្ធ | សូចនាករគន្លឹះ:<br>• ឆ្នាំ២០២៣៖ ផែនការបណ្តុះបណ្តាលប្រចាំឆ្នាំត្រូវបានរៀបចំដោយផ្អែកតាមសៀវភៅណែនាំស្តីពីការបណ្តុះបណ្តាល តម្រូវការជាក់ស្តែង និងផ្សារភ្ជាប់ទៅនឹងគោលបំណងផ្សេងទៀតនៅក្នុងផែនការយុទ្ធសាស្ត្រ<br>• ឆ្នាំ២០២៤៖ របាយការណ៍វាយតម្លៃលើការបណ្តុះបណ្តាលទាំងឡាយត្រូវបានរៀបចំ និងមានបង្ហាញអំពីស្ថានភាពនៃភាពស័ក្តិសិទ្ធិរបស់ផែនការបណ្តុះបណ្តាល |
|---|---|

| សកម្មភាពចម្បង | សូចនាករ | ក្របខណ្ឌពេលវេលា | ប្រភពធនធាន | ការទទួលខុសត្រូវ |
|---|---|---|---|---|
| ២.២.១ កែលម្អហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការបណ្តុះបណ្តាល និងសិក្ខាសាលា | • សម្ភារបរិក្ខារសម្រាប់ការបណ្តុះបណ្តាលត្រូវបានកែលម្អ<br>• អគារបណ្តុះបណ្តាលត្រូវបានបំពាក់សម្ភារបរិក្ខារគ្រប់គ្រាន់ | ២០២២ - ២០២៤ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.រដ្ឋបាល &ហិរ.<br>ន.បច្ចេកទេស |
| ២.២.២ ពង្រឹងគុណភាពនៃការរៀបចំវគ្គបណ្តុះបណ្តាល និងបង្កើនបរិមាណនៃការបណ្តុះបណ្តាល | • ផែនការបណ្តុះបណ្តាលប្រចាំឆ្នាំត្រូវបានរៀបចំដោយផ្អែកតាមសៀវភៅណែនាំស្តីពីការបណ្តុះបណ្តាល តម្រូវការជាក់ស្តែង និងផ្សារភ្ជាប់ទៅនឹងគោលបំណងផ្សេងទៀតនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ អ.ស.ជ<br>• សិក្ខាកាមចូលរួមទទួលបានចំណេះដឹង និងបទពិសោធន៍តាមការរំពឹងទុក | ២០២២ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.បច្ចេកទេស |
| ២.២.៣ ពង្រឹងគុណភាពនៃការរៀបចំសិក្ខាសាលា | • កម្មវិធីសិក្ខាសាលាប្រចាំឆ្នាំត្រូវរៀបចំត្រូវបានរៀបចំដោយផ្អែកតាមតម្រូវការជាក់ស្តែង និងផ្សារភ្ជាប់ទៅនឹងគោលបំណងផ្សេងទៀតនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ អ.ស.ជ<br>• សិក្ខាកាមចូលរួមទទួលបានចំណេះដឹង និងបទពិសោធន៍តាមការរំពឹងទុក | ២០២២ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.បច្ចេកទេស |

| គោលដៅយុទ្ធសាស្ត្រ<br>២.៣ បន្តអភិវឌ្ឍ និងពង្រឹងសេវាគាំទ្រដល់ការងារសេវនកម្ម | សូចនាករគន្លឹះ:<br>• ឆ្នាំ២០២៦៖ គ្រឿងបរិក្ខារប្រព័ន្ធព័ត៌មានវិទ្យានិងកម្មវិធីកុំព្យូទ័រដែលមានស្រាប់ និងតម្រូវការថ្មី ត្រូវបានបំពាក់ និងតម្លើង ស្របតាមតម្រូវការដែលបានគ្រោងក្នុងឆ្នាំ២០២៣ |
|---|---|

| សកម្មភាពចម្បង | សូចនាករ | ក្របខណ្ឌពេលវេលា | ប្រភពធនធាន | ការទទួលខុសត្រូវ |
|---|---|---|---|---|
| ២.៣.១. អភិវឌ្ឍសេវាគាំទ្រការងារសេវនកម្មពីប្រព័ន្ធបច្ចេកវិទ្យា ស្របតាមការវិវត្តនៃប្រព័ន្ធព័ត៌មានវិទ្យានៅក្នុងវិស័យសាធារណៈ | • តម្រូវការអំពីប្រព័ន្ធ/កម្មវិធីគ្រប់គ្រង ប្រព័ន្ធស្វ័យប្រវត្តិកម្មថ្មីៗ សម្រាប់គាំទ្រដល់ដំណើរការអនុវត្ត ការគ្រប់គ្រង និងការតាមដានការងារសេវនកម្មចាំបាច់នានាត្រូវបានកំណត់<br>• ឧបករណ៍/សម្ភារចាំបាច់សម្រាប់ប្រព័ន្ធ/កម្មវិធីគ្រប់គ្រង ប្រព័ន្ធស្វ័យប្រវត្តិកម្មថ្មីៗ សម្រាប់គាំទ្រដល់ដំណើរការអនុវត្ត ការគ្រប់គ្រង និងការតាមដានការងារសេវនកម្មចាំបាច់នានាត្រូវបានបំពាក់ ដាក់ឱ្យដំណើរការ និងថែទាំ | ២០២២ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.រដ្ឋបាល &ហិរ.<br>ន.បច្ចេកទេស |
| ២.៣.២. បង្កើនគុណភាពប្រព័ន្ធព័ត៌មានវិទ្យាដែលមានស្រាប់ | • ប្រព័ន្ធព័ត៌មានវិទ្យា (កម្មវិធីប្រឆាំងមេរោគ អាជ្ញាប័ណ្ណ ការបម្រុងទុក កម្មវិធី.....) និងគ្រឿងបរិក្ខារដែលមានស្រាប់ត្រូវបានស្ដារ និងថែទាំ | ២០២៣ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.បច្ចេកទេស |
| ២.៣.៣. កែលម្អប្រព័ន្ធតាមដាន និងរក្សាទុកឯកសារសេវនកម្ម | • ប្រព័ន្ធតាមដាន និងរក្សាទុកឯកសារសេវនកម្មត្រូវបានធ្វើបច្ចុប្បន្នភាព។<br>• គោលការណ៍ស្ដីពីការគ្រប់គ្រងឯកសាររបស់មជ្ឈមណ្ឌលរក្សាទុកឯកសារសេវនកម្មត្រូវបានអនុវត្តពេញលេញ។ | ២០២២ - ២០២៤ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.រដ្ឋបាល &ហិរ.<br>ន.បច្ចេកទេស |
| ២.៣.៤. ពង្រឹងសមត្ថភាពជំនាញនីតិកម្ម | • ក្រុមការងារត្រូវបានបង្កើតក្នុងការសិក្សាអំពីលទ្ធភាពក្នុងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងភារកិច្ចពាក់ព័ន្ធនឹងការងារនីតិកម្ម<br>• រចនាសម្ព័ន្ធគ្រប់គ្រង និងភារកិច្ចពាក់ព័ន្ធនឹងការងារនីតិកម្មត្រូវបានបង្កើត តាមការចាំបាច់<br>• សមត្ថភាពជំនាញត្រូវបានបណ្ដុះបណ្ដាល | ២០២៣ - ២០២៦ | អ.ស.ជ | ន.បច្ចេកទេស |

| សកម្មភាពចម្បង | សូចនាករ | ក្របខណ្ឌពេលវេលា | ប្រភពធនធាន | ការទទួលខុសត្រូវ |
|---|---|---|---|---|
| ២.៣.៥. ពង្រឹងសមត្ថភាពជំនាញព័ត៌មានវិទ្យា | • ក្រុមការងារត្រូវបានបង្កើតក្នុងការសិក្សាអំពីលទ្ធភាពក្នុងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងភារកិច្ចពាក់ព័ន្ធនឹងការងារព័ត៌មានវិទ្យា<br>• រចនាសម្ព័ន្ធគ្រប់គ្រង និងភារកិច្ចពាក់ព័ន្ធនឹងការងារព័ត៌មានវិទ្យាត្រូវបានបង្កើត តាមការចាំបាច់<br>• សមត្ថភាពជំនាញត្រូវបានបណ្តុះបណ្តាល | ២០២៣ - ២០២៦ | អ.ស.ជ | ន.បច្ចេកទេស |
| **គោលដៅយុទ្ធសាស្ត្រ**<br>**២.៤ បង្កើនការយល់ដឹង និងការអនុវត្តក្របខណ្ឌវាស់វែងការអនុវត្តរបស់ស្ថាប័នសវនកម្មកំពូល (SAI PMF) ក្នុងបរិបទរបស់ អ.ស.ជ** | | **សូចនាករគន្លឹះ:**<br>• ឆ្នាំ២០២៣៖ ការយល់ដឹងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអ.ស.ជ អំពី SAI PMF<br>• ឆ្នាំ២០២៥៖ SAI PMF ត្រូវបានប្រើប្រាស់ និងវាយតម្លៃ ដើម្បីមានមូលដ្ឋានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍បន្ទាប់កាន់តែគ្រប់ជ្រុងជ្រោយ | | |
| ២.៤.១ បង្កើនការយល់ដឹងរបស់ថ្នាក់ដឹកនាំ និងសវនករអំពី SAI PMF | • ដំណើរការអំពីរបៀបវាយតម្លៃ អ.ស.ជ ដោយប្រើប្រាស់ SAI PMF ត្រូវបានយល់ដឹង ហើយអាចអនុវត្ត ក្នុងឆ្នាំ២០២៣ | ២០២៣- ២០២៤ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.អន្តរជាតិ |
| ២.៤.២ អនុវត្តសាកល្បង SAI PMF | • របាយការណ៍វាយតម្លៃត្រូវបានរៀបចំ | ២០២៤- ២០២៥ | អ.ស.ជ | ន.អន្តរជាតិ |
| ២.៤.៣ ពង្រឹងការពិនិត្យតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឆ្នាំ២០២២ ដល់ឆ្នាំ២០២៦ | • ផែនការសកម្មភាពប្រចាំឆ្នាំត្រូវបានរៀបចំ អនុវត្ត និងពិនិត្យតាមដានទៀងទាត់ ដោយមានថវិកាសម្រាប់អនុវត្តគ្រប់គ្រាន់ | ២០២២ - ២០២៦ | អ.ស.ជ | ន.រដ្ឋបាល &ហិរ.<br>ន.អន្តរជាតិ |
| ២.៤.៤ ការត្រៀមលក្ខណៈសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្របន្ទាប់ | • សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍បន្ទាប់ ផ្អែកលើ SAI PMF ត្រូវបានរៀបចំក្នុងឆ្នាំ២០២៦ | ២០២៦ | អ.ស.ជ | ន.អន្តរជាតិ |

**គោលបំណងទី៣**

**«ពង្រឹងទំនាក់ទំនងរវាងសវនកម្មផ្ទៃក្រៅ និងផ្ទៃក្នុង ព្រមទាំងភាគីពាក់ព័ន្ធ ដើម្បីបង្កើនស័ក្តិសិទ្ធិភាពនៃលទ្ធផលសវនកម្ម »**

| គោលដៅយុទ្ធសាស្ត្រ | សូចនាករគន្លឹះ: |
|---|---|
| ៣.១ លើកកម្ពស់ការយល់ដឹង និងទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធខាងក្រៅអំពីមុខងារសវនកម្មផ្ទៃក្រៅ | • ភាពប្រសើរឡើងនៃទំនាក់ទំនងរវាងសវនកម្មផ្ទៃក្រៅ និងផ្ទៃក្នុង<br>• ភាគីពាក់ព័ន្ធខាងក្រៅទទួលបានការយល់ដឹងកាន់តែប្រសើរអំពីតួនាទីសវនកម្មផ្ទៃក្រៅ |

| សកម្មភាពចម្បង | សូចនាករ | ក្របខណ្ឌពេលវេលា | ប្រភពធនធាន | ការទទួលខុសត្រូវ |
|---|---|---|---|---|
| ៣.១.១ បង្កើនទំនាក់ទំនងជាមួយរដ្ឋសភា និងព្រឹទ្ធសភា | • ការទំនាក់ទំនង និងកិច្ចប្រជុំទៀងទាត់រវាងរដ្ឋសភា ព្រឹទ្ធសភា និងអ.ស.ជ ដើម្បីពិភាក្សាលើរបាយការណ៍សវនកម្មត្រូវបានរៀបចំ | ២០២២ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន. សវនកម្មទី១<br>ក្រុមការងារ |
| ៣.១.២ បង្កើនទំនាក់ទំនងជាមួយអង្គភាពរងសវនកម្ម | • ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជ្រួតជ្រាបកាន់តែច្បាស់ពីតួនាទី និងភារកិច្ចរបស់ អ.ស.ជ | ២០២២ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន. សវនកម្មទី១<br>ន. សវនកម្មទី២<br>ន. បច្ចេកទេស<br>ក្រុមការងារ |
| ៣.១.៣ ពង្រឹងទំនាក់ទំនងជាមួយសវនកម្មផ្ទៃក្នុង | • ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិធ្វើផែនការ និងរបាយការណ៍សវនកម្មផ្ទៃក្នុងបានទាន់ពេលវេលា | ២០២២ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន. សវនកម្មទី១<br>ន. សវនកម្មទី២<br>ន. បច្ចេកទេស<br>ក្រុមការងារ |
| ៣.១.៤ ពង្រឹងទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធខាងក្រៅផ្សេងទៀត | • សាធារណជនទូទៅ (សង្គមស៊ីវិល និងសារព័ត៌មាន) ទទួលបានការយល់ដឹងកាន់តែប្រសើរអំពីតួនាទីសវនកម្មផ្ទៃក្រៅ | ២០២២ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន. បច្ចេកទេស<br>ក្រុមការងារ |

| គោលដៅយុទ្ធសាស្ត្រ<br>៣.២ ពង្រឹង និងពង្រីកទំនាក់ទំនងជាមួយស្ថាប័នក្នុងតំបន់ និងអន្តរជាតិ ដើម្បីរួមចំណែកអភិវឌ្ឍន៍វិជ្ជាជីវៈសវនកម្មក្នុងបរិបទអន្តរជាតិ | សូចនាករគន្លឹះ:<br>• អ.ស.ជ បានចូលរួម និងមានទំនាក់ទំនងកាន់តែសកម្មជាមួយស្ថាប័នសវនកម្មកំពូល និងស្ថាប័នក្នុងតំបន់ និងអន្តរជាតិ | | | |
|---|---|---|---|---|
| **សកម្មភាពចម្បង** | **សូចនាករ** | **ក្របខណ្ឌពេលវេលា** | **ប្រភពធនធាន** | **ការទទួលខុសត្រូវ** |
| ៣.២.១ ពង្រឹង និងពង្រីកទំនាក់ទំនង និងការប្រាស្រ័យទាក់ទងជាមួយស្ថាប័នវិជ្ជាជីវៈ និងអង្គការក្នុងតំបន់ និងអន្តរជាតិពាក់ព័ន្ធ | • មន្ត្រីនៃអ.ស.ជ ទទួលបានឱកាសចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈរបស់ស្ថាប័នវិជ្ជាជីវៈ និងអង្គការក្នុងតំបន់ និងអន្តរជាតិពាក់ព័ន្ធ | ២០២២ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.បច្ចេកទេស<br>ន.អន្តរជាតិ |
| ៣.២.២ ជំរុញការចែករំលែកចំណេះដឹង និងបទពិសោធន៍ក្នុងបរិបថអន្តរជាតិដល់មន្ត្រីនៃ អ.ស.ជ | • មន្ត្រីនៃអ.ស.ជ ទទួលបានចំណេះដឹង និងបទពិសោធន៍ក្នុងបរិបថអន្តរជាតិ និងចែករំលែកគ្នាទៅវិញទៅមក តាមរយៈរបាយការណ៍ ឯកសារ ការធ្វើបទបង្ហាញ និងការបណ្តុះបណ្តាលជាដើម | ២០២២ - ២០២៦ | អ.ស.ជ<br>ដៃគូអភិវឌ្ឍន៍ | ន.បច្ចេកទេស<br>ន.អន្តរជាតិ |

## ៥. ការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ

ការសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រ ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ គឺអាស្រ័យលើការប្តេជ្ញាចិត្តយ៉ាងមុតមាំ និងការចូលរួមយ៉ាងសកម្មពីថ្នាក់ដឹកនាំ និងមន្ត្រីនៃ អ.ស.ជ ព្រមទាំងភាគីពាក់ព័ន្ធទាំងអស់។ លើសពីនេះ ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍នេះធ្វើឡើងទាន់ពេលវេលាត្រូវពឹងផ្អែកលើថវិកាគាំទ្រ ពីព្រោះ អ.ស.ជ ត្រូវការអ្នកពិគ្រោះការទីប្រឹក្សា និងសម្ភារ បរិក្ខារ ដើម្បីអនុវត្តសកម្មភាពគាំទ្រយុទ្ធសាស្ត្រទាំងនេះ។

ដូចនេះ អ.ស.ជ រំពឹងថានឹងមានថវិកាគាំទ្រគ្រប់គ្រាន់ ដើម្បីទទួលបានអ្នកពិគ្រោះការ ទីប្រឹក្សាផ្នែកបច្ចេកទេស និងសម្ភារ បរិក្ខារ ដើម្បីជួយធានានិរន្តរភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ។ ប្រសិនបើពុំមានធនធានគ្រប់គ្រាន់ទេ ផែនការយុទ្ធសាស្ត្រនេះអាចនឹងមានការកែប្រែ ហើយអាចអនុវត្តបានតែសកម្មភាពសំខាន់ៗបំផុតប៉ុណ្ណោះ។ ការប្រែប្រួលទាំងនេះនឹងឆ្លុះបញ្ចាំងនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ។

ក្រុមការងារត្រួតពិនិត្យ និងផ្តល់យោបល់លើការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍នឹងត្រូវបង្កើតសម្រាប់បំពេញភារកិច្ចត្រួតពិនិត្យលើការអនុវត្តផែនការយុទ្ធសាស្ត្រ ដើម្បីធានានូវភាពសមស្រប និងភាពទាន់ពេលវេលា ធៀបទៅនឹងផែនការសកម្មភាពដែលបានអនុម័តប្រចាំឆ្នាំ និងលទ្ធផលរំពឹងទុកដែលបានកំណត់។ ក្នុងករណីមានភាពរាំងស្ទះណាមួយលើដំណើរការអនុវត្តយុទ្ធសាស្ត្រ ក្រុមការងារនេះត្រូវរាយការណ៍ជូន និងស្នើសុំមតិណែនាំពីអគ្គសវនករ។ បន្ថែមលើនេះ ក្រុមការងារនេះត្រូវរៀបចំកិច្ចប្រជុំទៀងទាត់ (ប្រចាំត្រីមាស ឬប្រចាំឆមាស និងប្រចាំឆ្នាំ) ដើម្បីតាមដានការអនុវត្ត និងស្វែងរកដំណោះស្រាយបញ្ហានានាដែលអាចកើតមាននៅក្នុងពេលអនុវត្តផែនការយុទ្ធសាស្ត្រ ព្រមទាំងរាយការណ៍ជូនអគ្គសវនករអំពីការងារនេះ។

### ៥.១. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

#### ៥.១.១. កិច្ចប្រជុំតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ

ក- កិច្ចប្រជុំត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ ធ្វើឡើងដើម្បី៖

១- ពិនិត្យឡើងវិញនូវសកម្មភាពប្រចាំឆ្នាំ

២- ពិភាក្សាអំពីលទ្ធផល និងបញ្ហាប្រឈម និង

៣- កែសម្រួល ឬរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំខាងមុខ។

ខ- ការពិភាក្សាត្រូវផ្អែកលើរបាយការណ៍លទ្ធផលប្រចាំឆ្នាំរបស់នាយកដ្ឋាននីមួយៗ និងត្រូវបានគាំទ្រដោយលទ្ធផលនៃរបាយការណ៍វាយតម្លៃសកម្មភាពនៃសកម្មភាពដែលបានជ្រើសរើសក្នុងឆ្នាំ។

គ- គោលបំណងនៃការពិភាក្សា គឺជាការខិតខំប្រឹងប្រែងរួមគ្នា ដើម្បីឈានទៅរកការសម្រេចចិត្តដ៏ត្រឹមត្រូវ ដើម្បីធ្វើឱ្យកិច្ចខិតខំប្រឹងប្រែងរួមគ្នានេះទទួលបានជោគជ័យ។

ឃ- កិច្ចប្រជុំតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ ត្រូវរៀបចំឡើងក្នុងត្រីមាសទី៤ នៃឆ្នាំនីមួយៗ។

ង- ការពិនិត្យឡើងវិញ និងកែសម្រួលផែនការការងាររបស់នាយកដ្ឋាន និងសកម្មភាពនីមួយៗ គឺជាលទ្ធផលនៃកិច្ចប្រជុំត្រួតពិនិត្យ និងវាយតម្លៃ។

### ៥.១.២. ដំណើរការត្រួតពិនិត្យ និងវាយតម្លៃ

ក- ដំណើរការត្រួតពិនិត្យ និងវាយតម្លៃ គឺជាវដ្តដែលបន្តជាអចិន្ត្រៃយ៍ និងជះឥទ្ធិពលដល់ការធ្វើផែនការ ការអនុវត្ត និងការតាមដានសកម្មភាពនីមួយៗដែលបានកំណត់ ។

ខ- នាយកដ្ឋានដើរតួនាទីយ៉ាងសំខាន់ក្នុងកម្រិតសកម្មភាព ដើម្បីធានាបាននូវការរៀបចំផែនការលម្អិត ការអនុវត្តសកម្មភាព ការតាមដានរាល់សកម្មភាពដែលបានគ្រោងទុកប្រចាំឆ្នាំ និងការធ្វើរបាយការណ៍ ដោយមានការលើកសំណើកែសម្រួលយុទ្ធសាស្ត្រប្រសិនបើមាន ។

គ- នៅកម្រិតយុទ្ធសាស្ត្រមាន ៤ ដំហានដើម្បីធានានូវដំណើរការការត្រួតពិនិត្យ និងវាយតម្លៃបន្ត៖

(១) ការរៀបចំរបាយការណ៍វឌ្ឍនភាពរបស់នាយកដ្ឋាន

(២) ការរៀបចំរបាយការណ៍លទ្ធផលប្រចាំឆ្នាំរបស់នាយកដ្ឋាន

(៣) ដំណើរការនៃកិច្ចប្រជុំតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ និង

(៤) ការបង្ហាញរបាយការណ៍លទ្ធផលប្រចាំឆ្នាំជូនថ្នាក់ដឹកនាំជាន់ខ្ពស់ ដើម្បីពិនិត្យ និងអនុម័ត។

ឃ- នាយកដ្ឋានបញ្ជូនរបាយការណ៍វឌ្ឍនភាពរបស់នាយកដ្ឋានទៅក្រុមការងារដែលបានកំណត់នៅសប្តាហ៍ទីមួយនៃខែវិច្ឆិកា។ ដោយផ្អែកលើរបាយការណ៍ដែលទទួលបានក្រុមការងារនឹងរៀបចំសេចក្តីព្រាងរបាយការណ៍លទ្ធផលប្រចាំឆ្នាំសម្រាប់កិច្ចប្រជុំតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ។ ប្រសិនបើចាំបាច់ ក្រុមការងារនេះ នឹងលើកសំណើសុំកែសម្រួលយុទ្ធសាស្ត្រជូនថ្នាក់ដឹកនាំ ដើម្បីពិនិត្យ និងសម្រេច។

## ៥.២. របាយការណ៍វឌ្ឍនភាពរបស់នាយកដ្ឋាន

ក- របាយការណ៍វឌ្ឍនភាពរបស់នាយកដ្ឋាន គឺជារបាយការណ៍ដែលប្រើប្រាស់ដោយនាយកដ្ឋានដើម្បីរាយការណ៍អំពីកម្រិតនៃការអនុវត្តសកម្មភាព និងការសម្រេចបាននូវគោលបំណង និងលទ្ធផល។ របាយការណ៍នេះបង្ហាញអំពីការសម្រេចបាននូវគោលដៅយុទ្ធសាស្ត្ររបស់ អ.ស.ជ និងផ្តល់ព័ត៌មានថាតើស្ថានភាពនៃសកម្មភាពរបស់ អ.ស.ជ ស្ថិតនៅចំណុចណា និងតើអាចសម្រេចបានលទ្ធផលតាមការរំពឹងទុកដែរឬទេ។

ខ- របាយការណ៍វឌ្ឍនភាពរបស់នាយកដ្ឋាន រួមមានការរៀបរាប់ដោយសង្ខេបអំពីការវាយតម្លៃសកម្មភាពទាំងអស់របស់នាយកដ្ឋានក្នុងឆ្នាំ។ របាយការណ៍នេះបង្ហាញអំពីការអនុវត្តផែនការសកម្មភាពដែលទទួលបន្ទុកដោយនាយកដ្ឋានសាមី និងការវាយតម្លៃអំពីការរួមចំណែករបស់សកម្មភាពដែលត្រូវបានអនុវត្តក្នុងការសម្រេចបានតាមគោលដៅយុទ្ធសាស្ត្រ និងសូចនាករដែលបានកំណត់។ របាយការណ៍នេះក៏បង្ហាញអំពីជំហានបន្ទាប់ដែលត្រូវអនុវត្ត ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រដែលបានរំពឹងទុក។

គ- របាយការណ៍វឌ្ឍនភាពរបស់នាយកដ្ឋានត្រូវបង្ហាញអំពី "ការត្រួតពិនិត្យដំណើរការ" និង "ការត្រួតពិនិត្យលទ្ធផល" ។ របាយការណ៍វឌ្ឍនភាពនេះ នឹងត្រូវបានប្រើដើម្បីរំលេចព័ត៌មានសំខាន់ពីសកម្មភាពទាំងអស់ដែលនាយកដ្ឋានបានអនុវត្តកន្លងមក។

ឃ- របាយការណ៍វឌ្ឍនភាពរបស់នាយកដ្ឋាន ផ្តល់នូវទិដ្ឋភាពទូទៅសម្រាប់ថ្នាក់ដឹកនាំ លើការអនុវត្តសកម្មភាពនៅក្នុងផ្នែកដែលជាការទទួលខុសត្រូវរបស់នាយកដ្ឋាន។ ម៉្យាងវិញទៀត របាយការណ៍នេះនឹងជូនដំណឹងអំពីវឌ្ឍនភាពឆ្ពោះទៅរកគោលបំណងដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ អ.ស.ជ ។

ង- របាយការណ៍វឌ្ឍនភាពរបស់នាយកដ្ឋាន រួមមានៈ

១) ការពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពនៃការអនុវត្តផែនការការងាររបស់នាយកដ្ឋាន ការប្រៀបធៀបផែនការ និងការអនុវត្តជាក់ស្តែងទាក់ទងនឹងពេលវេលា ថវិកា (ប្រសិនបើមាន) និងលទ្ធផលរំពឹងទុក។

២) ការឆ្លុះបញ្ចាំងពីភាពមិនស្របគ្នារវាងផែនការ និងការអនុវត្ត និងការពន្យល់ពីមូលហេតុនៃការខុសគ្នានេះ។

៣) លើកសំណើអំពីវិធីសាស្ត្រ ឬមធ្យោបាយថ្មី ជូនថ្នាក់ដឹកនាំ អ.ស.ជ ដើម្បីជម្នះបញ្ហាប្រឈមដែលបានកើតឡើង នៅក្នុងពេលអនុវត្តផែនការការងារ ប្រសិនបើលទ្ធផលដែលសម្រេចបានមិនរួមចំណែកដល់គោលដៅយុទ្ធសាស្ត្រដូចការរំពឹងទុក។ ប្រសិនបើចាំបាច់ លើកសំណើបង្កើតក្រុមការងារដើម្បីពន្លឿនការអនុវត្តសកម្មភាពដែលនាយកដ្ឋានទទួលខុសត្រូវ ។

## ៥.៣. របាយការណ៍លទ្ធផលប្រចាំឆ្នាំ

ក- របាយការណ៍លទ្ធផលប្រចាំឆ្នាំ ផ្តល់នូវការវាយតម្លៃលើវឌ្ឍនភាពឆ្ពោះទៅរកលទ្ធផលជាក់លាក់ និងសូចនាករសំខាន់ៗ រួមជាមួយនឹងការរៀបរាប់ដោយសង្ខេប។

ខ- របាយការណ៍លទ្ធផលប្រចាំឆ្នាំ គឺផ្អែកលើទិដ្ឋភាពសង្ខេបនៃសកម្មភាពដែលបានអនុវត្ត និងដែលបានចងក្រងដោយក្រុមការងារ។ ជារៀងរាល់ឆ្នាំក្នុងអំឡុងខែវិច្ឆិកាដល់ខែធ្នូ ក្រុមការងារត្រូវរៀបចំកិច្ចប្រជុំតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំលើវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ហើយនឹងត្រូវរាយការណ៍អំពីលទ្ធផល ដំណោះស្រាយលើបញ្ហាប្រឈម និងកំណត់ទិសដៅអនុវត្តបន្តជូនដល់ថ្នាក់ដឹកនាំជាន់ខ្ពស់ ដើម្បីពិនិត្យ និងអនុម័ត។

គ- ការផ្តោតសំខាន់នៃរបាយការណ៍នេះ គឺលើការសម្រេចបាននូវគោលបំណង និងគោលដៅយុទ្ធសាស្ត្ររបស់ អ.ស.ជ ។ ជាមួយនឹងការសង្កត់ធ្ងន់លើបញ្ហាយុទ្ធសាស្ត្ររបាយការណ៍នេះនឹងគូសបញ្ជាក់ថាតើការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ អ.ស.ជ ស្ថិតនៅចំណុចណា ឬថាតើគួរត្រូវចាត់វិធានការកែតម្រូវដែរឬទេ។

ឃ- វឌ្ឍនភាពឆ្ពោះទៅរកគោលបំណង និងគោលដៅជាយុទ្ធសាស្ត្រពាក់ព័ន្ធយ៉ាងខ្លាំងចំពោះការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំ។ ប្រសិនបើគោលបំណង និងគោលដៅយុទ្ធសាស្ត្រដែលបានគ្រោងទុកមិនបានសម្រេចដូចការរំពឹងទុក ថ្នាក់ដឹកនាំត្រូវតែវិភាគរកហេតុផលនៃគម្លាត ឬភាពខុសគ្នានេះ ហើយត្រូវពិភាក្សារកយុទ្ធសាស្ត្រកែតម្រូវ ។ ដូច្នេះ របាយការណ៍នេះនឹងផ្តល់ជាមូលដ្ឋានសម្រាប់ការៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ដែលអនុញ្ញាតឱ្យ អ.ស.ជ កែសម្រួលយុទ្ធសាស្ត្រអនុវត្តសម្របទៅនឹងការវិវត្តជាក់ស្តែងបានទាន់ពេលវេលា និងតាមការចាំបាច់។

# ឧបសម្ព័ន្ធទី១៖ ទម្រង់គំរូនៃផែនការសកម្មភាពប្រចាំឆ្នាំ

| សកម្មភាព | លទ្ធផលរំពឹងទុក | ក្របខណ្ឌពេលវេលា | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | តម១ | តម២ | តម៣ | តម៤ | |
| *គោលបំណងទី១ «កសាង និងពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងគុណភាពសវនកម្ម ដើម្បីធ្វើឱ្យកាន់តែប្រសើរក្នុងការលើកកម្ពស់អភិបាលកិច្ចល្អក្នុងវិស័យសាធារណៈ»* | | | | | | |
| គោលដៅយុទ្ធសាស្ត្រ ១.១ ការពង្រឹងសមត្ថភាព និងគុណភាពសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល(ISSAIs) | | | | | | |
| មូលដ្ឋានគោល | | សូចនាករគន្លឹះ | | | | |
| ១.១.១. (សកម្មភាពចម្បង) | | | | | | |
| (១). (អនុសកម្មភាព) | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

# ឧបសម្ព័ន្ធទី២៖ គម្រោងថវិកា (ឆ្នាំ២០២២-ឆ្នាំ២០២៦)

| បរិយាយ | គម្រោងថវិកាតាមឆ្នាំ (រៀល) | | | | | |
|---|---|---|---|---|---|---|
| | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | ឆ្នាំ២០២៥ | ឆ្នាំ២០២៦ | សរុប |
| គោលដៅយុទ្ធសាស្ត្រ ១.១ ការពង្រឹងសមត្ថភាព និងគុណភាពសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល(ISSAIs) | | | | | | |
| ការរៀបចំចងក្រង និងកែសម្រួលឯកសារបណ្តុះបណ្តាល | 8 000 000 | 8 000 000 | 8 000 000 | 8 000 000 | 8 000 000 | 40 000 000 |
| បណ្តុះបណ្តាលមន្ត្រី (ក្នុងប្រទេស) | 12 750 000 | 12 750 000 | 12 750 000 | 12 750 000 | 12 750 000 | 63 750 000 |
| បណ្តុះបណ្តាលគ្រូបង្គោល (ក្នុងប្រទេស) | 11 500 000 | 11 500 000 | 11 500 000 | 11 500 000 | 11 500 000 | 57 500 000 |
| សិក្ខាសាលា បណ្តុះបណ្តាល និងកិច្ចប្រជុំ (ក្រៅប្រទេស) | 42 000 000 | 42 000 000 | 42 000 000 | 42 000 000 | 42 000 000 | 210 000 000 |
| ការសិក្សាលទ្ធភាពធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំ | | | | | 2 000 000 | 2 000 000 |
| បោះពុម្ព និងបកប្រែ | 2 000 000 | 2 000 000 | 4 000 000 | 2 000 000 | 10 000 000 | 20 000 000 |
| គោលដៅយុទ្ធសាស្ត្រ ១.២. ការពង្រឹងសមត្ថភាព និងគុណភាពសវនកម្មលើកិច្ចប្រតិបត្តិការ ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល(ISSAIs) | | | | | | |
| សិក្ខាសាលា និងកិច្ចប្រជុំ (ក្នុងប្រទេស) | 8 000 000 | 8 000 000 | 8 000 000 | 8 000 000 | 8 000 000 | 40 000 000 |
| ការបណ្តុះបណ្តាលមន្ត្រី (ក្នុងប្រទេស) | 12 750 000 | 12 750 000 | 12 750 000 | 12 750 000 | 12 750 000 | 63 750 000 |
| ការបណ្តុះបណ្តាលគ្រូបង្គោល (ក្នុងប្រទេស) | 11 500 000 | 11 500 000 | 11 500 000 | 11 500 000 | 11 500 000 | 57 500 000 |
| សិក្ខាសាលា បណ្តុះបណ្តាល និងកិច្ចប្រជុំ (ក្រៅប្រទេស) | 42 000 000 | 42 000 000 | 42 000 000 | 42 000 000 | 42 000 000 | 210 000 000 |
| ការសិក្សាលទ្ធភាពធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំ | | | | | 2 000 000 | 2 000 000 |
| បោះពុម្ព និងបកប្រែ | 2 000 000 | 2 000 000 | 4 000 000 | 2 000 000 | 10 000 000 | 20 000 000 |

| បរិយាយ | គម្រោងថវិកាតាមឆ្នាំ (រៀល) | | | | | |
|---|---|---|---|---|---|---|
| | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | ឆ្នាំ២០២៥ | ឆ្នាំ២០២៦ | សរុប |
| គោលដៅយុទ្ធសាស្ត្រ១.៣. ការពង្រឹងសមត្ថភាព និងគុណភាពសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល(ISSAIs) | | | | | | |
| សិក្ខាសាលា និងកិច្ចប្រជុំ (ក្នុងប្រទេស) | 8 000 000 | 8 000 000 | 8 000 000 | 8 000 000 | 8 000 000 | 40 000 000 |
| ការបណ្តុះបណ្តាលមន្ត្រី (ក្នុងប្រទេស) | 12 750 000 | 12 750 000 | 12 750 000 | 12 750 000 | 12 750 000 | 63 750 000 |
| ការបណ្តុះបណ្តាលគ្រូបង្គោល (ក្នុងប្រទេស) | 11 500 000 | 11 500 000 | 11 500 000 | 11 500 000 | 11 500 000 | 57 500 000 |
| សិក្ខាសាលា បណ្តុះបណ្តាល និងកិច្ចប្រជុំ (ក្រៅប្រទេស) | 42 000 000 | 42 000 000 | 42 000 000 | 42 000 000 | 42 000 000 | 210 000 000 |
| ការសិក្សាលទ្ធភាពធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំ | | | | | 2 000 000 | 2 000 000 |
| បោះពុម្ព និងបកប្រែ | 2 000 000 | 2 000 000 | 4 000 000 | 2 000 000 | 10 000 000 | 20 000 000 |
| គោលដៅយុទ្ធសាស្ត្រ ១.៤. ការពង្រឹងសមត្ថភាព និងគុណភាពសវនកម្មលើប្រភេទសវនកម្មជាក់លាក់ ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល(ISSAIs) | | | | | | |
| សិក្ខាសាលា និងកិច្ចប្រជុំ (ក្នុងប្រទេស) | | 4 000 000 | 4 000 000 | 4 000 000 | 4 000 000 | 16 000 000 |
| ការបណ្តុះបណ្តាលមន្ត្រី (ក្នុងប្រទេស) | | 8 850 000 | 8 850 000 | 8 850 000 | 8 850 000 | 35 400 000 |
| ការបណ្តុះបណ្តាលគ្រូបង្គោល (ក្នុងប្រទេស) | | 11 500 000 | 11 500 000 | 11 500 000 | 11 500 000 | 46 000 000 |
| សិក្ខាសាលា បណ្តុះបណ្តាល និងកិច្ចប្រជុំ (ក្រៅប្រទេស) | | 18 000 000 | 18 000 000 | 18 000 000 | 18 000 000 | 72 000 000 |
| ការសិក្សាលទ្ធភាពធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំ | | | | 2 000 000 | 2 000 000 | 4 000 000 |
| បោះពុម្ព និងបកប្រែ | 2 000 000 | 2 000 000 | 2 000 000 | 2 000 000 | 5 000 000 | 13 000 000 |
| គោលដៅយុទ្ធសាស្ត្រ ១.៥ បន្តអភិវឌ្ឍ និងពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងធានាគុណភាពសម្រាប់គ្រប់ប្រភេទសវនកម្ម | | | | | | |
| សិក្ខាសាលា និងកិច្ចប្រជុំ (ក្នុងប្រទេស) | | 9 000 000 | 18 000 000 | 9 000 000 | 18 000 000 | 54 000 000 |
| ការបណ្តុះបណ្តាលមន្ត្រី (ក្នុងប្រទេស) | | 8 850 000 | 8 850 000 | 8 850 000 | 8 850 000 | 35 400 000 |

| បរិយាយ | គម្រោងថវិកាតាមឆ្នាំ (រៀល) | | | | | |
|---|---|---|---|---|---|---|
| | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | ឆ្នាំ២០២៥ | ឆ្នាំ២០២៦ | សរុប |
| ការបណ្តុះបណ្តាលគ្រូបង្គោល (ក្នុងប្រទេស) | | 11 500 000 | 11 500 000 | 11 500 000 | 11 500 000 | 46 000 000 |
| សិក្ខាសាលា បណ្តុះបណ្តាល និងកិច្ចប្រជុំ (ក្រៅប្រទេស) | | 30 000 000 | 30 000 000 | 30 000 000 | 30 000 000 | 120 000 000 |
| ការងារវាយតម្លៃអនុលោមភាពនៃការងារសវនកម្មទៅនឹងស្តង់ដារ និងគោលការណ៍ណែនាំ | | | 18 000 000 | | 18 000 000 | 36 000 000 |
| បោះពុម្ព និងបកប្រែ | | 1 000 000 | 1 000 000 | 1 000 000 | 1 000 000 | 4 000 000 |
| គោលដៅយុទ្ធសាស្ត្រ ១.៦ បង្កើនស័ក្តិសិទ្ធិភាពនៃការអនុវត្តអនុសាសន៍សវនកម្ម | | | | | | |
| សិក្ខាសាលា និងកិច្ចប្រជុំ (ក្នុងប្រទេស) | | 18 000 000 | 12 000 000 | 18 000 000 | 18 000 000 | 66 000 000 |
| សិក្ខាសាលា បណ្តុះបណ្តាល និងកិច្ចប្រជុំ (ក្រៅប្រទេស) | | 51 250 000 | 51 250 000 | | | 102 500 000 |
| សិក្សា និងតម្លើងប្រព័ន្ធ | | | | 205 000 000 | 205 000 000 | 410 000 000 |
| បោះពុម្ព និងបកប្រែ | 1 000 000 | 1 000 000 | 6 150 000 | 1 000 000 | 1 000 000 | 10 150 000 |
| គោលដៅយុទ្ធសាស្ត្រ ១.៧ ការធ្វើបច្ចុប្បន្នភាពស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យស្របតាមការវិវត្តនៃស្តង់ដារអន្តរជាតិ | | | | | | |
| សិក្ខាសាលា និងកិច្ចប្រជុំ (ក្នុងប្រទេស) | | | | 9 000 000 | 9 000 000 | 18 000 000 |
| បោះពុម្ព និងបកប្រែ | | | | 5 000 000 | 5 000 000 | 10 000 000 |
| គោលដៅយុទ្ធសាស្ត្រ ២.១. ពង្រឹងការគ្រប់គ្រងធនធានមនុស្ស | | | | | | |
| សិក្ខាសាលា និងកិច្ចប្រជុំ (ក្នុងប្រទេស) | 4 000 000 | 4 000 000 | 4 000 000 | 4 000 000 | 4 000 000 | 20 000 000 |
| សិក្សា និងតម្លើងប្រព័ន្ធ | | | 82 000 000 | | | 82 000 000 |
| បោះពុម្ព និងបកប្រែ | 1 000 000 | 1 000 000 | 5 000 000 | 5 000 000 | 1 000 000 | 13 000 000 |

| បរិយាយ | គម្រោងថវិកាតាមឆ្នាំ (រៀល) | | | | | |
|---|---|---|---|---|---|---|
| | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | ឆ្នាំ២០២៥ | ឆ្នាំ២០២៦ | សរុប |
| **គោលដៅយុទ្ធសាស្ត្រ ២.២. ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ដើម្បីពង្រឹងជំនាញវិជ្ជាជីវៈសវនកម្ម និងជំនាញពាក់ព័ន្ធ** | | | | | | |
| ការបណ្តុះបណ្តាលមន្ត្រី (ក្នុងប្រទេស) | 10 250 000 | 10 250 000 | 10 250 000 | 10 250 000 | 10 250 000 | 51 250 000 |
| សិក្ខាសាលា បណ្តុះបណ្តាល និងកិច្ចប្រជុំ (ក្រៅប្រទេស) | | 51 250 000 | | 51 250 000 | | 102 500 000 |
| បំពាក់សម្ភារ បរិក្ខារ | 205 000 000 | 205 000 000 | | | | 410 000 000 |
| ថែទាំ និងជួសជុលសម្ភារ បរិក្ខា | | | 20 500 000 | 20 500 000 | 20 500 000 | 61 500 000 |
| បោះពុម្ព និងបកប្រែ | 1 000 000 | 1 000 000 | 1 000 000 | 1 000 000 | 1 000 000 | 5 000 000 |
| **គោលដៅយុទ្ធសាស្ត្រ ២.៣ បន្តអភិវឌ្ឍ និងពង្រឹងសេវាគាំទ្រដល់ការងារសវនកម្ម** | | | | | | |
| សិក្ខាសាលា និងកិច្ចប្រជុំ (ក្នុងប្រទេស) | 4 100 000 | | | | | 4 100 000 |
| ការបណ្តុះបណ្តាល (ក្នុងប្រទេស) | | 10 250 000 | 10 250 000 | 10 250 000 | 10 250 000 | 41 000 000 |
| ទីប្រឹក្សាបច្ចេកទេស | | 41 000 000 | | 41 000 000 | | 82 000 000 |
| សិក្សា និងតម្លើងប្រព័ន្ធ | | 102 500 000 | 102 500 000 | 102 500 000 | 102 500 000 | 410 000 000 |
| បំពាក់សម្ភារ បរិក្ខារ | | 41 000 000 | | 41 000 000 | | 82 000 000 |
| ថែទាំ និងជួសជុលសម្ភារ បរិក្ខា | 20 500 000 | 20 500 000 | 20 500 000 | 20 500 000 | 20 500 000 | 102 500 000 |
| បោះពុម្ព និងបកប្រែ | 1 000 000 | 1 000 000 | 1 000 000 | 1 000 000 | 1 000 000 | 5 000 000 |
| **គោលដៅយុទ្ធសាស្ត្រ ២.៤ បង្កើនការយល់ដឹង និងការអនុវត្តក្របខណ្ឌវាស់វែងការអនុវត្តរបស់ស្ថាប័នសវនកម្មកំពូល (SAI PMF) ក្នុងបរិបទរបស់ អ.ស.ជ** | | | | | | |
| សិក្ខាសាលា និងកិច្ចប្រជុំ (ក្នុងប្រទេស) | 30 750 000 | 30 750 000 | 20 500 000 | 20 500 000 | 20 500 000 | 123 000 000 |
| សិក្ខាសាលា បណ្តុះបណ្តាល និងកិច្ចប្រជុំ (ក្រៅប្រទេស) | | 30 750 000 | 30 750 000 | | | 61 500 000 |
| បោះពុម្ព និងបកប្រែ | 1 000 000 | 1 000 000 | 1 000 000 | 1 000 000 | 1 000 000 | 5 000 000 |

| បរិយាយ | គម្រោងថវិកាតាមឆ្នាំ (រៀល) | | | | | |
|---|---|---|---|---|---|---|
| | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | ឆ្នាំ២០២៥ | ឆ្នាំ២០២៦ | សរុប |
| គោលដៅយុទ្ធសាស្ត្រ ៣.១ លើកកម្ពស់ការយល់ដឹង និងទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធខាងក្រៅអំពីមុខងារសេវនកម្មផ្ទៃក្រៅ | | | | | | |
| សិក្ខាសាលា និងកិច្ចប្រជុំ (ក្នុងប្រទេស) | | 106 600 000 | 106 600 000 | 106 600 000 | 106 600 000 | 426 400 000 |
| បោះពុម្ព និងបកប្រែ | | 2 050 000 | 2 050 000 | 2 050 000 | 2 050 000 | 8 200 000 |
| គោលដៅយុទ្ធសាស្ត្រ ៣.២ ពង្រឹង និងពង្រីកទំនាក់ទំនងជាមួយស្ថាប័នក្នុងតំបន់ និងអន្តរជាតិ ដើម្បីរួមចំណែកអភិវឌ្ឍន៍វិជ្ជាជីវៈសវនកម្មក្នុងបរិបទអន្តរជាតិ | | | | | | |
| សិក្ខាសាលា និងកិច្ចប្រជុំ (ក្នុងប្រទេស) | 4 100 000 | 4 100 000 | 4 100 000 | 4 100 000 | 4 100 000 | 20 500 000 |
| សិក្ខាសាលា បណ្តុះបណ្តាល និងកិច្ចប្រជុំ (ក្រៅប្រទេស) | 205 000 000 | 205 000 000 | 205 000 000 | 205 000 000 | 205 000 000 | 1 025 000 000 |
| បោះពុម្ព និងបកប្រែ | 1 000 000 | 1 000 000 | 1 000 000 | 1 000 000 | 1 000 000 | 5 000 000 |
| សរុប | 720 450 000 | 1273 700 000 | 1063 850 000 | 1221 950 000 | 1144 700 000 | 5 424 650 000 |
| ចំណាយផ្សេងៗ (៥%) | 36 022 500 | 63 685 000 | 53 192 500 | 61 097 500 | 57 235 000 | 271 232 500 |
| សរុបរួម | 756 472 500 | 1 337 385 000 | 1117 042 500 | 1 283 047 500 | 1 201 935 000 | 5 695 882 500 |

**កំណត់សម្គាល់:** គម្រោងថវិកាខាងលើគឺជាការប៉ាន់ស្មានសម្រាប់ទ្រទ្រង់ការអនុវត្តសម្រាប់សកម្មភាព និងអនុសកម្មភាពនៃគោលដៅជាយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍នេះតែប៉ុណ្ណោះ ។